# សង្គមស៊ីវិល
# និង
# ចំណូលធនធាន

## ករណីសិក្សានៃ
## ប្រទេសអាហ្សែបៃហ្សង់ និង ប្រទេសទីម័រឡេស្តេ



ភ្នំពេញ ខែធ្នូ ឆ្នាំ ២០០៨

# សង្គមស៊ីវិល
# និង
# ចំណូលធនធាន

## ករណីសិក្សានៃ
## ប្រទេសអាហ្សែរបៃហ្សង់ និង ប្រទេសទីម័រឡេស្តេ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
*The NGO Forum on Cambodia*

ភ្នំពេញ ខែធ្នូ ឆ្នាំ ២០០៨

# មាតិកា


សេចក្តីថ្លែងអំណរគុណ..........១
បុព្វកថា..........២
១. ប្រទេសអាហ្វ្រិកខាងលិច..........៤
១.១ សាវតា..........៤
១.២ បញ្ហាសំខាន់ៗ..........៦
១.២.១ មូលនិធិប្រេងកាត..........៧
១.២.២ គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម..........៧
១.៣ សម្ព័ន្ធភាពសង្គមស៊ីវិល..........១០
១.៤ វិធីសាស្ត្រនៃការពាក់ព័ន្ធ..........១១
១.៤.១ ជាមួយសង្គមស៊ីវិល..........១១
១.៤.២ ជាមួយរដ្ឋាភិបាល..........១៤
១.៤.៣ ជាមួយសាជីវកម្ម..........១៥
២. ប្រទេសទីម័រឡេស្តេ..........១៧
២.១ សាវតា..........១៧
២.២ បញ្ហាសំខាន់ៗ..........១៩
២.២.១ មូលនិធិប្រេងកាត..........១៩
២.២.២ គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម..........២០
២.៣ សម្ព័ន្ធភាពសង្គមស៊ីវិល..........២១
២.៤ វិធីសាស្ត្រនៃការពាក់ព័ន្ធ..........២២
២.៤.១ ជាមួយសង្គមស៊ីវិល..........២២
២.៤.២ ជាមួយរដ្ឋាភិបាល..........២៥
២.៤.៣ ជាមួយសាជីវកម្ម..........២៧
៣. មេរៀនសម្រាប់សង្គមស៊ីវិល..........២៨
៣.១ បង្កើតសម្ព័ន្ធភាពតំណាងមួយ..........២៨
៣.២ ផ្តោតលើបញ្ហាគន្លឹះ: EITI..........២៨

៣.៣ ផ្តោតលើបញ្ហាគន្លឹះ: មូលនិធិប្រេងកាត..................................................................៣០
៣.៤ ពាក់ព័ន្ធសង្គមស៊ីវិល ..........................................................................................៣១
៣.៥ ពាក់ព័ន្ធរដ្ឋាភិបាល.............................................................................................៣២
៣.៦ ពាក់ព័ន្ធក្រុមហ៊ុន...............................................................................................៣៣
៤. ឈ្មោះអក្សរកាត់..................................................................................................៣៥

## សេចក្តីថ្លែងអំណរគុណ

កូនសៀវភៅនេះត្រូវបានផលិតដោយគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដោយមានការជួយឧបត្ថម្ភមូលនិធិមួយផ្នែកពីអង្គការអុកស្វាមអាមេរិក (Oxfam America)។ កូនសៀវភៅនេះបានទទួលការផ្តល់មតិយោបល់ដ៏មានតម្លៃ និងកិច្ចសហការពីតំណាងសង្គមស៊ីវិលនៅក្នុងប្រទេសអាហ្សែរបៃហ្សង់ និងប្រទេសទីម័រឡេស្តេ និងការពិភាក្សានៅក្នុងចំណោមនៃតំណាងសម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន (CRRT)។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអង្គការ និងបុគ្គលទាំងឡាយដែលបានរួមចំណែកដល់ការបោះពុម្ពផ្សាយកូនសៀវភៅនេះ។

សៀវភៅណែនាំនេះត្រូវបានផលិត បោះពុម្ពផ្សាយ និងកែសម្រួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ក្នុងខែធ្នូ ឆ្នាំ ២០០៨។ ខ្លឹមសារនៃឯកសារនេះអាចដកស្រង់ ឬផលិតឡើងវិញបានសម្រាប់គោលបំណងអភិវឌ្ឍន៍ ប៉ុន្តែគប្បីមានការទទួលស្គាល់អ្នកបោះផ្សាយ។

# បុព្វកថា

ប្រទេសកម្ពុជាមានធនធានធម្មជាតិជាច្រើន ដូចជាមាស ស្ពាន់ បុកស៊ីដ ប្រេងកាត និងឧស្ម័នជាដើម ។ ក្រុមហ៊ុនអន្តរជាតិជាច្រើនមកពីប្រទេសនានា ដូចជា អាមេរិក អូស្ត្រាលី ចិន កូរ៉េ គូវ៉ែត ម៉ាឡេស៊ី និងស៊ុយអែដ បានចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលក្នុងការរុករកប្រេងកាត ឧស្ម័ន និងរ៉ែនៅក្នុងដែនដីកម្ពុជា។ ក្រុមហ៊ុនរ៉ែកំពុងធ្វើសកម្មភាពនៅក្នុងខេត្តមួយចំនួន ដូចជាកំពង់ធំ មណ្ឌលគិរី និងរតនគិរី ខណៈដែលក្រុមហ៊ុនប្រេងកាតកំពុងធ្វើការរុករកនៅក្នុងសមុទ្រ និងនៅក្នុងតំបន់ជុំវិញអាងបឹងទន្លេសាប ។ ថ្វីបើការរុករកភាគច្រើន គឺស្ថិតនៅក្នុងដំណាក់កាលដំបូងក្តី ក៏វាគឺជាប្រការប្រាកដប្រជាដែរ ដែលការរុករកទាំងនេះខ្លះៗនឹងប្រែក្លាយទៅជាការធ្វើអាជីវកម្មដែលនាំមកនូវប្រាក់ចំណូលសន្ធឹកសន្ធាប់ជូនរាជរដ្ឋាភិបាល ។ មានការប៉ាន់ស្មានថា ចំណូលធនធានដែលបានពីមួយផ្នែកនៃវិស័យនិស្សារណកម្ម អាចផ្តល់ចំណូលដល់រាជរដ្ឋាភិបាលពី ១៧៤ លានដុល្លារក្នុងឆ្នាំ ២០១១ ដល់ ១.៧ ពាន់លានដុល្លារក្នុងឆ្នាំ២០២១ (*ប្រភព: IMF ២០០៧ របាយការណ៍ថ្នាក់ជាតិរបស់ IMF លេខ ០៧/២៩១*) ។

ក្តីសង្ឃឹមគឺថាប្រទេសកម្ពុជានឹងមិនពឹងផ្អែកលើជំនួយអភិវឌ្ឍន៍ និងថាសេដ្ឋកិច្ចរបស់ប្រទេសនឹងរីកលូតលាស់តាមរបៀបមួយដែលនឹងជម្រុញឱ្យមានកំណើនខ្ពស់ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍបន្ថែមទៀតនូវហេដ្ឋារចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ច ។ ប៉ុន្តែបទពិសោធន៍អន្តរជាតិបង្ហាញថា ការគ្រប់គ្រងមិនល្អលើចំណូលធនធានធម្មជាតិសន្ធឹកសន្ធាប់ ក៏អាចប៉ះពាល់ជាអវិជ្ជមានផងដែរលើបរិយាកាសម៉ាក្រូសេដ្ឋកិច្ច ដែលអាចមានផលវិបាកធ្ងន់ធ្ងរលើសេដ្ឋកិច្ច កិច្ចអភិវឌ្ឍន៍សង្គម និងស្ថេរភាពនយោបាយ ។

កូនសៀវភៅនេះបង្ហាញពីករណីសិក្សាថាតើសង្គមស៊ីវិលនៅប្រទេសអាហ្សែរបៃហ្សង់ និងប្រទេសទីម័រឡេស្តេ បានធ្វើចលនាយ៉ាងដូចម្តេចដើម្បីមានឥទ្ធិពលលើគណនេយ្យភាព និងតម្លាភាពក្នុងការគ្រប់គ្រងចំណូលប្រេងកាត និងឧស្ម័ន។ កូនសៀវភៅនេះគឺជាសេចក្តីសង្ខេបមួយនៃឯកសារស្រាវជ្រាវដ៏ពេញលេញមួយ ដែលបានពិនិត្យមើលការអភិវឌ្ឍន៍ ការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងឧស្សាហកម្មប្រេងកាតនៅប្រទេសអាហ្សែរបៃហ្សង់ និងប្រទេសទីម័រឡេស្តេ ។ ការសិក្សាដើម និងពេញលេញនេះមានផ្តល់ជូននៅក្នុងស៊ីឌីភ្ជាប់ជាមួយកូនសៀវភៅនេះ ។ នៅក្នុងស៊ីឌីនេះផងដែរ ក៏មានឧបសម្ព័ន្ធនានាដែលបានលើកឡើងនៅក្នុងអត្ថបទនេះ ក៏ដូចជាបទបង្ហាញ Power Point ដែលសង្ខេបខ្លឹមសារសៀវភៅនេះ និងដែលអាចប្រើបាននៅក្នុងសិក្ខាសាលានានា ។

គោលបំណងនៃកូនសៀវភៅនេះ គឺសំដៅផ្ដល់ធនធានមួយជូនដល់ក្រុមសង្គមស៊ីវិលកម្ពុជា និងក្រុមសង្គមស៊ីវិលនៃប្រទេសផ្សេងទៀត ដើម្បីដឹកនាំ និងផ្ដល់ឧទាហរណ៍អំពីរបៀបដែលសង្គមស៊ីវិលអាចចូលរួមក្នុងវិស័យធនធាន និងកែលម្អការគ្រប់គ្រងប្រាក់ចំណូល ។ មេរៀននានាសម្រាប់សង្គមស៊ីវិល ដែលមានបង្ហាញនៅក្នុងកូនសៀវភៅនេះ គឺគ្រាន់តែសម្រាប់ជាការណែនាំមួយប៉ុណ្ណោះ ពីព្រោះប្រទេសនីមួយៗមានបរិបទសង្គម សេដ្ឋកិច្ច និងនយោបាយដោយឡែកផ្ទាល់ខ្លួន ។ ហេតុនេះយុទ្ធសាស្ត្រ និងអភិក្រមចូលរួមត្រូវតែកែច្នៃយ៉ាងជាក់លាក់ស្របតាមលក្ខណៈពិសេសនៃវប្បធម៌ ដែលនៅក្នុងនោះគេព្យាយាមអនុវត្តយុទ្ធសាស្ត្រ និងអភិក្រមទាំងនេះ ។ ប៉ុន្តែ បញ្ហានៃតម្លាភាព និងគណនេយ្យភាពចំណូលធនធានហាក់បីដូចជាមានលក្ខណៈដូចគ្នានៅក្នុងប្រទេសក្រីក្រដែលពឹងផ្អែកលើធនធាន ។ កូនសៀវភៅនេះ ត្រូវបានសង្ឃឹមថាជួយសម្រួលវិធានការឆ្លើយតប ដែលបានរៀបចំយ៉ាងជាក់លាក់ទៅនឹងបញ្ហាផ្ដែករចនាសម្ព័ន្ធ និងអភិបាលកិច្ចទូទៅសម្រាប់ក្រុមសង្គមស៊ីវិលណាដែលមានបំណងប្រាថ្នាចែករំលែកភោគទ្រព្យរួមក្នុងលក្ខណៈយុត្តិធម៌ និងសមធម៌ ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកូនសៀវភៅនេះ រួមចំណែកដល់ការយល់ដឹងអំពីរបៀបដែលសង្គមស៊ីវិលអាចរិះរកច្រកដើម្បីពាក់ព័ន្ធក្នុងលក្ខណៈស្ថាបនាជាមួយរាជរដ្ឋាភិបាល ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលផ្សេងទៀត និងរួមចំណែកដល់ការគ្រប់គ្រងចំណូលធនធានធម្មជាតិ ។



ឈិត សំអាត

នាយកប្រតិបត្តិ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា

# ប្រទេសអាស៊ែបៃហ្សង់

## សាវតា

| | |
|---|---|
| **ចំនួនប្រជាជន ៖** | ៨.១២០.២៤៧ |
| **សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ៖** | ៩៨ , ១៧៧ |
| **ជីវិតរំពឹង ៖** | ៦៥-៩៦ ឆ្នាំ |
| **ចំនួនប្រជាជនក្រោមបន្ទាត់ក្រីក្រ ៖** | ២៤% |
| **ផលិតផលក្នុងស្រុកសរុប-ក្នុងប្រជាជនម្នាក់ (PPP)៖** | ៩.០០០ ដុល្លារ |
| **ប្រេងកាត - ផលិតកម្ម ៖** | ៩៣៤.៧០០ ធុង/ថ្ងៃ |
| **ឧស្ម័នធម្មជាតិ - ផលិតកម្ម ៖** | ៦,៣ ពាន់លានសង់ទីម៉ែត្រគីប |
| **ចំណូលពីប្រេងកាតនិងឧស្ម័ន ៖** | ៤,៥ ពាន់លានដុល្លារ (២០០៧) |

**នាំចេញ៖** ទំនិញ - ប្រេងកាត និងឧស្ម័ន ៩០%, គ្រឿងម៉ាស៊ីន កប្បាស គ្រឿងស្បៀងអាហារ




*ប្រភព៖ សៀវភៅព័ត៌មានពិភពលោក (The World Factbook)*[3]

*http://www.cia.gov/library/publications/the-world-factbook/geos/aj.html*

ប្រទេសអាហ៊្សែរបៃហ្សង់ បានទទួលឯករាជ្យពេញលេញវិញក្រោយពេលដែលសហភាពសូវៀត បានដួលរលំនៅក្នុងឆ្នាំ ១៩៩១ ។ ក្នុងឋានៈជាប្រទេសផលិតប្រេងដ៏សំខាន់ អាហ៊្សែរបៃហ្សង់អាចផលិតប្រេងក្នុងកម្រិតអតិបរមាក្នុងអំឡុងឆ្នាំ ២០១០ ហើយធនធាននេះ អាចនឹងត្រូវអស់ក្នុងរយៈពេល ២០ ឆ្នាំ ។ ថ្មីៗនេះ ប្រេងកាត បាននាំឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ ជាមួយផលិតផលក្នុងស្រុកសរុប (GDP) កើនឡើង ៣២% ក្នុងឆ្នាំ ២០០៦ ដែលបណ្ដាលមកពីតម្លៃប្រេងកាតឡើងខ្ពស់ និងកំណើនផលិតកម្ម ។ កំណើនសេដ្ឋកិច្ចលឿនកំពុងដាក់សម្ពាធ ដ៏ធំធេងលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គមដែលមានលក្ខណៈមិនគ្រប់គ្រាន់ និងទ្រុឌទ្រោម ។ ទន្ទឹមនឹងនេះ លំហូរចូលនៃចំណូលបរទេសពីការនាំចេញប្រេងកាតកំពុងបំប្លែងសណ្ឋានពិតនៃសេដ្ឋកិច្ច ។ ភាពក្រីក្រនៅមានកម្រិតខ្ពស់ប្រហែល ២០% ។

វិស័យប្រេងកាត និងឧស្ម័នគឺមានចំណែកប្រហែល ៥៤% នៃផលិតផលក្នុងស្រុកសរុប ។ ចំណូលរដ្ឋាភិបាលប្រហែលមួយភាគបី គឺបានមកពីក្រុមហ៊ុនប្រេងកាតរដ្ឋ និង១៧% ពីមូលនិធិប្រេងកាតរដ្ឋ (SOFAZ) ។ ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ SOFAZ បានឡើងដល់ ១,៨ ពាន់លាននៅចុងឆ្នាំ ២០០៦ ។ SOFAZ ចាយចំណូលប្រេងកាតរបស់ខ្លួនភាគច្រើនលើកម្មវិធីសង្គម និងហេដ្ឋារចនាសម្ព័ន្ធ ។ ក្រុមហ៊ុនរដ្ឋផ្ដាច់មុខទាំងនេះបំប្លែងសណ្ឋានពិតនៃសេដ្ឋកិច្ច តាមរយៈការអនុវត្តដែលមានលក្ខណៈប្រឆាំងការប្រកួតប្រជែង ខ្វះអភិបាលកិច្ចសាជីវកម្ម និងប្រតិបត្តិដោយគ្មានប្រសិទ្ធភាពដែលធ្វើឱ្យមានការខាតបង់ធ្ងន់ធ្ងរពីការឧបត្ថម្ភធន ។ គេឃើញមានវិធានការវិជ្ជមានដែលត្រូវបានអនុវត្តដើម្បី កាត់បន្ថយឧបត្ថម្ភធន ហើយក្រុមហ៊ុនប្រេងកាតរដ្ឋបានចាប់ផ្ដើមអនុវត្តកំណែទម្រង់អភិបាលកិច្ចស្របតាមគំនិតផ្ដួចផ្ដើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ។

មានក្ដីសង្ឃឹមខ្ពស់ក្នុងការងារអភិវឌ្ឍន៍ប្រទេសក្នុង ខណៈដែលរដ្ឋាភិបាលព្យាយាម សម្រេចឱ្យបានតាម ការសន្យារបស់ខ្លួន លើការលើកស្ទួយកម្រិតជីវភាពនៅក្នុងបរិបទនៃសមត្ថភាពស្ថាប័នដ៏មានកម្រិតការធ្វើសេចក្ដីសម្រេចចិត្តប្រកបដោយមជ្ឈការខ្ពស់ភាពផ្ដាច់មុខអំពើពុករលួយ និងប្រព័ន្ធតតិយុត្តិគ្មានប្រសិទ្ធិភាព ។ រដ្ឋាភិបាលទទួលស្គាល់ថាខ្លួនត្រូវតែអនុវត្តកំណែទម្រង់ និងគោលនយោបាយចាំបាច់ ទាំងឡាយដែលនឹងជួយឱ្យសេដ្ឋកិច្ចរីកលូតលាស់ ។ ចំពោះមុខស្ថានភាពនេះ រដ្ឋាភិបាលនៃប្រទេសអាហ៊្សែរបៃហ្សង់ បានអនុវត្តកម្មវិធីមួយចំនួន ដើម្បីជម្រុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាពនៅក្នុងវិស័យក្រៅពីប្រេងកាត ស្ដារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តទ្រុឌទ្រោម និងកាត់បន្ថយគម្លាតរវាងតំបន់នានារបស់ប្រទេស ។

*ព័ត៌មានអំពីប្រទេសអាហ៊្សែរបៃហ្សង់: http://www.adb.org/Documents/Books/ADO/2007/AZE.asp*

## បញ្ហាសំខាន់ៗ

ការងាររួមនៃសម្ព័ន្ធភាពសង្គមស៊ីវិលនៅជុំវិញគណនេយ្យភាព និងតម្លាភាព ចំណូលធនធាន មានលក្ខណៈទូលំទូលាយ (កិច្ចសន្យា និងការផ្តល់អាជ្ញាប័ណ្ណ ការទូទាត់ប្រាក់ថ្លៃឈ្នួលពន្ធលំហូរប្រាក់ចំណូល និងការធ្វើថវិកា)។ ប៉ុន្តែ ជារឿយៗ គេឃើញមានបញ្ហាសំខាន់ៗ ជាក់លាក់ដែលកំណត់ប្រភេទនៃសម្ព័ន្ធភាព (ដូចជាក្រុមថវិកាជាតិជាដើម) ឬក៏បង្ហាញវិស័យក្រៅការងារដែលទំនងជាធ្វើឱ្យមានការប្រែប្រួលចំពោះការគ្រប់គ្រងចំណូលធនធាន។ នៅប្រទេសអាហ្វ្រិកខាងត្បូងវិស័យក្រៅការងារទាំងនេះជាក់ស្តែង គឺការគ្រប់គ្រងមូលនិធិប្រេងកាត និងកិច្ចដំណើរការអនុវត្តគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI)។

### តើមូលនិធិប្រេងកាតគឺជាអ្វី?

មូលនិធិប្រេងកាតគឺសំដៅដោះស្រាយបញ្ហាទាំងឡាយ ដែលបានបង្កើតឡើងដោយភាពប្រែប្រួលនៃចំណូលប្រេងកាត (មូលនិធិ 'ស្ថេរភាពកម្ម') និងភាពចាំបាច់ត្រូវសន្សំប្រាក់ចំណូលប្រេងកាត សម្រាប់មនុស្សជំនាន់ក្រោយ (មូលនិធិ 'ប្រាក់សន្សំ' ឬ 'អភិវឌ្ឍន៍')។

មូលនិធិស្ថេរភាពកម្ម សំដៅដោះស្រាយបញ្ហានៃចំណូលប្រេងកាតដែលមិនអាចព្យាករណ៍បាន។ នៅពេលចំណូលប្រេងកាតខ្ពស់ ចំណូលមួយចំនួនត្រូវបានដាក់ចូលទៅក្នុងមូលនិធិស្ថេរភាពកម្ម។ នៅពេលចំណូលប្រេងកាតទាប មូលនិធិស្ថេរភាព កម្មផ្តល់ហិរញ្ញប្បទានលើកង្វះខាតថវិកា។ ប្រការនេះធ្វើឱ្យចំណូល និងចំណាយថវិកាមានស្ថេរភាព។

មូលនិធិប្រាក់សន្សំ ទទួលចំណែកថេរមួយនៃចំណូលប្រេងកាត ដែលត្រូវបានសន្សំទុកជាស្វ័យប្រវត្តិសម្រាប់មនុស្សជំនាន់ក្រោយ។ ប្រសិនបើមូលនិធិទាំងនេះ ទទួលបានជោគជ័យ វាត្រូវតែនាំទៅដល់ប្រាក់សន្សំសរុបខ្ពស់របស់រដ្ឋាភិបាល។

អំណះអំណាងគាំទ្រមូលនិធិប្រេងកាតផ្សេងទៀត គឺដើម្បីទប់ទល់ "ជម្ងឺហូឡង់" - ដែលកើតឡើងនៅពេលដែលវិស័យថាមពលលូតលាស់ធ្វើឱ្យខូចខាតវិស័យទំនិញ និងសេវាកម្ម ដែលអាចធ្វើពាណិជ្ជកម្មបាននៃសេដ្ឋកិច្ច។

មូលនិធិអាចធ្វើឱ្យការសន្សំប្រាក់មានលក្ខណៈនយោបាយកាន់តែងាយស្រួល ប៉ុន្តែការសន្សំប្រាក់តម្រូវឱ្យមានការសម្រេចចិត្តលើគោលនយោបាយសារពើពន្ធផ្សេងទៀត ហើយ ប្រសិនបើ អ្នកនយោបាយមានបំណងចង់ចាយមូលនិធិ ទំនងជាមិនអាចរារាំងពួកគេបានទេ។ លើសពីនេះទៀត មូលនិធិធំមួយ អាចបង្កើតឱ្យមានសម្ពាធចាយថែមទៀត - អ្នកបោះឆ្នោតអាច ចោទសួរថាហេតុអ្វីបានជាចាំបាច់ ត្រូវបង់ពន្ធខ្ពស់នៅពេលដែលមូលនិធិមានប្រាក់ច្រើនសន្ធឹកសន្ធាប់ហើយនោះ។ម្យ៉ាងទៀត មូលនិធិប្រេងកាត អាចត្រូវបានដាក់បញ្ចូលមិនបានល្អទៅក្នុងថវិកា ដែលអាចនាំទៅដល់ការបាត់បង់ការគ្រប់គ្រងសារពើពន្ធជារួម និងបង្កើតបញ្ហានៃការសម្របសម្រួលចំណាយ ដូចជា ចំណាយត្រួតគ្នា ឬការសម្រេចចិត្តចំណាយមូលធនដែលត្រូវបានធ្វើដោយមិនមានការពិចារណាអំពីផលវិបាកជាដើម។

អភិបាលកិច្ច តម្លាភាព និងគណនេយ្យភាព អាចធ្វើឱ្យអន្តរាយដល់មូលនិធិប្រេងកាត។ ជាចរិតលក្ខណៈរបស់វាតែម្តង ជាធម្មតា មូលនិធិប្រេងកាត គឺស្ថិតនៅក្រៅប្រព័ន្ធថវិកា ហើយជារឿយៗ គឺទទួលខុសត្រូវចំពោះតែអ្នកនយោបាយមួយចំនួន តូចប៉ុណ្ណោះ។ ប្រការនេះ ធ្វើឱ្យមូលនិធិនេះងាយរងការប្រើបំពាន និងការជ្រៀតជ្រែកនយោបាយ។ លក្ខខណ្ឌរាយការណ៍ និងសវនកម្មសម្រាប់មូលនិធិទាំងនេះច្រើនមានលក្ខណៈធូររលុង ហើយកង្វះខាតការដាក់បញ្ចូលមូលនិធិទាំងនេះទៅក្នុងប្រព័ន្ធ ថវិកាកាន់តែធ្វើឱ្យមានការលំបាកទាំងចំពោះរដ្ឋសភា និងទាំងចំពោះសាធារណជនក្នុងការឃ្លាំមើលការប្រើធនធានសាធារណៈជារួម។

*http://www.imf.org/external/pubs/ft/fandd/2001/12/davis.htm*

## មូលនិធិប្រេងកាត

មូលនិធិប្រេងកាតរដ្ឋអាស៊ែប៊ែហ្សង់ (SOFAZ) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៩ ជាមូលនិធិប្រាក់សន្សំមួយ សម្រាប់មនុស្សជំនាន់ក្រោយពីប្រាក់ចំណូលដែលបានមកពីឧស្សាហកម្មប្រេងកាត និងឧស្ម័ន។ ជាបឋម មូលនិធិនេះ វិនិយោគរូបិយប័ណ្ណបរទេស និងទ្រព្យឥតសកម្មបានមកពីការរុករក និងការអភិវឌ្ឍប្រេងកាត និងឧស្ម័នលើមូលប័ត្រដែលមានហានិភ័យទាប ។

មូលនិធិទាំងនេះត្រូវបានដាក់បញ្ចូលក្នុងថវិការដ្ឋ ស្របតាមការកំណត់តាមផ្លូវច្បាប់ដែលថាចំណាយសរុបមិនត្រូវលើសចំណូលរំពឹងនៃមូលនិធិនៅក្នុងឆ្នាំដដែលឡើយ ។ មូលនិធិពី SOFAZ ត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោង ជាក់លាក់នានា ដូចដែលមានកំណត់នៅក្នុងក្រឹត្យរបស់ប្រធានាធិបតី និងត្រូវបានផ្ទេរថវិកាទៅវិស័យទាំងនោះ ។ អំណាចធ្វើសេចក្តីសម្រេចចិត្តទាក់ទិន នឹងការគ្រប់គ្រង SOFAZ រួមទាំងការបញ្ចេញមូលនិធិរបស់ SOFAZ គឺស្ថិតនៅក្នុងដៃរបស់ប្រធានាធិបតី( តាមរយៈក្រឹត្យរបស់ប្រធានាធិបតី) ។

ទស្សនៈរបស់សង្គមស៊ីវិលនៅ ក្នុងប្រទេសអាស៊ែប៊ែហ្សង់ គឺថាការត្រួតពិនិត្យរបស់រដ្ឋសភាលើថវិការដ្ឋជាទូទៅគឺមានលក្ខណៈទន់ខ្សោយ ។ លើសពីនេះទៀត គោលដៅចំណាយរបស់ SOFAZ ត្រូវកំណត់ក្នុងលក្ខណៈទូលាយ ដែលបើកចំហចំពោះការបកស្រាយ ។ តួនាទីរបស់សង្គមស៊ីវិលនៅក្នុងការឃ្លាំមើលការជម្រុញការយល់ដឹង និងការតស៊ូមតិ ដើម្បីការគ្រប់គ្រងមូលនិធិឱ្យបានសមស្រប ការរៀបចំថវិកា និងការជ្រើសរើសគម្រោង គឺមានសារសំខាន់ក្រៃលែងសម្រាប់កិច្ចអភិវឌ្ឍន៍ជាតិរឹងមាំ និងដើម្បីឱ្យប្រទេសជៀសផុតពី ‘ជម្ងឺហូឡង់’ ។

ប្រទេសអាស៊ែប៊ែហ្សង់ទទួលជំនួយពីរដ្ឋាភិបាលណ័រវ៉េ ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដើម្បីគ្រប់គ្រងប្រតិបត្តិការរបស់ SOFAZ ។

*គេហទំព័ររបស់ SOFAZ[3] www.oilfund.az*

*ព័ត៌មានបន្ថែមអំពី SOFAZ អាចរកបាននៅក្នុងឧបសម្ព័ន្ធ E នៅក្នុងស៊ីឌីភ្ជាប់ជាមួយនេះ*

*ព័ត៌មានបន្ថែមអំពីជម្ងឺហូឡង់ នៅក្នុងឧបសម្ព័ន្ធ B នៅក្នុងស៊ីឌីភ្ជាប់ជាមួយនេះ*

## គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI)

ក្នុងឆ្នាំ ២០០២ នាយករដ្ឋមន្ត្រី អង់គ្លេសនៅពេលនោះ លោក តូនី ប្លែរ បានផ្តួចផ្តើម EITI (គំនិតផ្តួចផ្តើមស្ម័គ្រចិត្តមួយ) ។ កិច្ចដំណើរការសកលលោកនៃ EITI បង្រួបបង្រួមឱ្យមានសម្ព័ន្ធភាពមួយនៃក្រុមហ៊ុន រដ្ឋាភិបាល វិនិយោគិន និងអង្គការសង្គមស៊ីវិល ដើម្បីសហការគ្នាដើម្បីតម្លាភាព

និងគណនេយ្យភាពកាន់តែច្រើនឡើងរបស់រដ្ឋាភិបាល តាមរយៈការបញ្ចេញព័ត៌មានសាធារណៈកាន់តែល្អប្រសើរឡើង និងការត្រួតពិនិត្យឯករាជ្យលើប្រាក់ចំណូល ប្រេងកាត ឧស្ម័ន និងរ៉ែ។ លេខាធិការដ្ឋាន EITI គឺស្ថិតនៅក្នុងក្រុងអូស្លូ ប្រទេសណ័រវេ។

ចំណុចគន្លឹះមួយនៅក្នុងការអនុវត្ត EITI គឺការចូលរួមរបស់សមាជិក ឯករាជ្យនៃសង្គមស៊ីវិល។ លក្ខណៈវិនិច្ឆ័យ EITI ទី ៥ ចែងថាៈ *សង្គមស៊ីវិល ចូលរួមយ៉ាងសកម្ម ជាអ្នកចូលរួមមួយនៅក្នុងការរៀបចំ ការឃ្លាំមើល និងការវាយតម្លៃកិច្ចដំណើរការនេះ និងរួមចំណែកដល់ការពិភាក្សាសាធារណៈ*។

ប្រទេសអាហ្វ្រិកខាងត្បូង បានអនុម័ត EITI នៅក្នុងខែមិថុនា ឆ្នាំ ២០០៣ និងបានប្តេជ្ញាចំពោះការអនុវត្ត ដោយចេញផ្សាយរបាយការណ៍ EITI ទីមួយរបស់ខ្លួនក្នុងឆ្នាំ ២០០៥។ ចាប់តាំងពីពេលនោះមកប្រទេសអាហ្វ្រិកខាងត្បូង បានផ្សព្វផ្សាយរបាយការណ៍ EITI ចំនួនប្រាំពីររួចហើយ (របាយការណ៍ប្រចាំឆមាស និងរបាយការណ៍ប្រចាំឆ្នាំ)។ កិច្ចដំណើរការ របាយការណ៍ពាក់ព័ន្ធសវនករឯករាជ្យមួយ ដែលត្រូវបានជ្រើសរើសដោយក្រុមការងារត្រីភាគីមួយដែលមានសង្គមស៊ីវិល រដ្ឋាភិបាល និងតំណាងឧស្សាហកម្ម ដែលវាយតម្លៃលើការបង់ប្រាក់របស់ក្រុមហ៊ុន ប្រៀបធៀបទៅនឹងព័ត៌មានបង់ប្រាក់ដែលផ្តល់ដោយរដ្ឋាភិបាល។ ក្រោយពេលបញ្ចប់របាយការណ៍មួយរបស់សវនករឯករាជ្យត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដែលរួមមានសេចក្តីអត្ថាធិប្បាយរបស់សវនករលើភាពខុសគ្នាណាមួយ ដែលត្រូវបានរកឃើញ។

## គោលការណ៍នៃគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម

១. យើងមានជំនឿរួមគ្នាថាការប្រើប្រាស់ភោគទ្រព្យធនធានធម្មជាតិដ៏ប្រុងប្រយ័ត្ន គប្បីគឺជាក្បាលម៉ាស៊ីនដ៏សំខាន់មួយ សម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពដែលរួមចំណែកដល់កិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែប្រសិនបើ មិនគ្រប់គ្រងឱ្យបានសមស្របទេ អាចនាំមកនូវផលប៉ះពាល់ខាងសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងលក្ខណៈអវិជ្ជមាន ។

២. យើងសូមអះអាងថា ការគ្រប់គ្រងភោគទ្រព្យធនធានធម្មជាតិសម្រាប់អត្ថប្រយោជន៍របស់ប្រជាពលរដ្ឋរបស់ប្រទេស គឺស្ថិតនៅក្នុងសមត្ថកិច្ចរបស់រដ្ឋាភិបាលអធិបតេយ្យ ដែលត្រូវប្រើប្រាស់ដើម្បីផលប្រយោជន៍នៃកិច្ចអភិវឌ្ឍន៍ប្រទេសជាតិខ្លួន ។

៣. យើងទទួលស្គាល់ថាអត្ថប្រយោជន៍នៃនិស្សារណកម្មធនធានកើតឡើងជាលំហូរចំណូលក្នុងរយៈពេលច្រើនឆ្នាំ និងអាចមានលក្ខណៈពឹងផ្អែកខ្លាំងលើតម្លៃ ។

៤. យើងទទួលស្គាល់ថា ការយល់ដឹងរបស់សាធារណជនអំពីចំណូល និងចំណាយរបស់រដ្ឋាភិបាល អាចជួយដល់ការពិភាក្សាជាសាធារណៈ និងជូនព័ត៌មានដល់ការជ្រើសរើសយកជម្រើសដ៏សមស្រប និងប្រាកដប្រជាសម្រាប់កិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។

៥. យើងយល់ដឹងអំពីសារសំខាន់នៃការអនុវត្តតម្លាភាពដោយរដ្ឋាភិបាល និងក្រុមហ៊ុនទាំងឡាយនៅក្នុងឧស្សាហកម្មនិស្សារណកម្ម និងភាពចាំបាច់ត្រូវកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណនេយ្យភាព ។

៦. យើងទទួលស្គាល់ថា ការសម្រេចបាននូវតម្លាភាពកាន់តែច្រើនឡើងត្រូវតែបានកំណត់នៅក្នុងបរិបទនៃការគោរពកិច្ចសន្យា និងច្បាប់ ។

៧. យើងទទួលស្គាល់នូវការលើកកម្ពស់បរិកាសសម្រាប់វិនិយោគផ្ទាល់ក្នុងស្រុក និងបរទេស បានមកពីតម្លាភាពហិរញ្ញវត្ថុ ។

៨. យើងមានជំនឿលើគោលការណ៍ និងការអនុវត្តគណនេយ្យភាពដោយរដ្ឋាភិបាល ចំពោះប្រជាពលរដ្ឋទាំងអស់សម្រាប់ការគ្រប់គ្រងចំណូល និងចំណាយសាធារណៈ ។

៩. យើងប្តេជ្ញាលើកទឹកចិត្ត ឱ្យអនុវត្តនូវស្តង់ដារខ្ពស់នៃតម្លាភាព និងគណនេយ្យភាពនៅក្នុងជីវិតសាធារណៈប្រតិបត្តិការរដ្ឋាភិបាល និងនៅក្នុងអាជីវកម្ម ។

១០. យើងជឿថាចាំបាច់ត្រូវមានអភិក្រមប្រកបដោយសង្គតិភាព និងដែលអាចអនុវត្តបានយ៉ាងទូលាយមួយ ចំពោះការបញ្ចេញព័ត៌មានអំពីការបង់ប្រាក់ និងប្រាក់ចំណូល ។

១១. យើងជឿថាការបញ្ចេញព័ត៌មានអំពីការបង់ប្រាក់នៅក្នុងប្រទេសមួយ គប្បីពាក់ព័ន្ធគ្រប់ក្រុមហ៊ុនឧស្សាហកម្មនិស្សារណកម្មទាំងអស់ដែលធ្វើប្រតិបត្តិការនៅក្នុងប្រទេសនោះ ។

១២. ក្នុងការស្វែងរកដំណោះស្រាយ យើងជឿថាភាគីពាក់ព័ន្ធទាំងអស់ សុទ្ធតែមានសារសំខាន់ និងមានការពាក់ពន្ធ័ក្នុងការរួមចំណែក- រួមទាំងរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាល ក្រុមហ៊ុនឧស្សាហកម្មនិស្សារណកម្ម ក្រុមហ៊ុនផ្តល់សេវាកម្ម អង្គការពហុភាគី គ្រឹះស្ថានហិរញ្ញវត្ថុ វិនិយោគិន និងអង្គការមិនមែនរដ្ឋាភិបាល ។

## លក្ខណៈវិនិច្ឆ័យដើម្បីអនុវត្តគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម

១. ការផ្សព្វផ្សាយដ៏ទៀងទាត់ក្នុងលក្ខណៈដែលអាចទទួលបានយ៉ាងពេញលេញជាសាធារណៈនូវការបង់ប្រាក់ច្រើនសម្រាប់ប្រេងកាត ឧស្ម័ន និងរ៉ែ ដោយក្រុមហ៊ុន ជូនរដ្ឋាភិបាល (ការបង់ប្រាក់) និងគ្រប់ចំណូលធំៗ ទាំងអស់ដែលទទួល ដោយរដ្ឋាភិបាលពីក្រុមហ៊ុនប្រេងកាត ឧស្ម័ន និងរ៉ែ (ចំណូល) ជូនដល់សាធារណជន ។

២. នៅទីណាដែលមិនទាន់មានសវនកម្មបែបនេះ ការបង់ប្រាក់ និងប្រាក់ចំណូលគឺជាកម្មវត្ថុនៃសវនកម្មឯករាជ្យដែលអាចទុកចិត្តបានដោយអនុវត្តស្តង់ដារសវនកម្មអន្តរជាតិ ។

៣. ការបង់ប្រាក់ និងប្រាក់ចំណូលត្រូវបានផ្ទៀងផ្ទាត់ដោយរដ្ឋបាលឯករាជ្យដោយអនុវត្តស្តង់ដារសវនកម្មអន្តរជាតិជាមួយនឹងការផ្សព្វផ្សាយយោបល់របស់រដ្ឋបាល អំពីការផ្ទៀងផ្ទាត់នេះ រួមទាំងចំណុចមិនស្របគ្នានានា ប្រសិនបើត្រូវបានរកឃើញ ។

៤. អភិក្រមនេះ ត្រូវអនុវត្តលើគ្រប់ក្រុម- ហ៊ុនទាំងអស់ រួមទាំងសហគ្រាសរដ្ឋផងដែរ ។

៥. សង្គមស៊ីវិលចូលរួមយ៉ាងសកម្ម ជាអ្នកចូលរួមមួយនៅក្នុងការរៀបចំការឃ្លាំមើល និងការវាយតម្លៃកិច្ចដំណើរការនេះ និងរួមចំណែកដល់ការពិភាក្សាជាសាធារណៈ ។

EITI: www.eitransparency.org

*គោលការណ៍ និងលក្ខណៈវិនិច្ឆ័យ EITI*
*មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ H*
*នៅក្នុងស៊ីឌីភ្ជាប់ជាមួយនេះ*

# សម្ព័ន្ធភាពសង្គមស៊ីវិល

## ការឃ្លាំមើលថវិកាជាតិ

ក្រុមថវិកាជាតិ (NBG) ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ ២០០៦។ NBG មានគម្រោងដើម្បីឃ្លាំមើល និងតាមដានចំណាយថវិកាផ្សេងៗ រៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលានានាជូនក្រុមសង្គមស៊ីវិល/ក្រុមសារព័ត៌មាន មានឯកសារបោះពុម្ពផ្សាយមួយចំនួនអំពីបញ្ហាថវិកាដែលប្រើភាសាសាមញ្ញ និងអាចយល់បាន និងសហការក្នុងការឃ្លាំមើលរួមគ្នាជាមួយក្រសួងរដ្ឋាភិបាលមួយចំនួន។ NBG កំពុងបង្កើតបណ្តាញថវិកាប្រកបដោយតម្លាភាពមួយ ដែលចូលរួមពីសង្គមស៊ីវិលកាន់តែច្រើនឡើង។

*ក្រុមថវិកាជាតិ: http://www.nbg.az/index.php?lang=en&menu=main*
*សមាជិកនៃ NBG មានជម្រាបជូននៅក្នុងឧបសម្ព័ន្ធ I នៅក្នុងស៊ីឌីភ្ជាប់ជាមួយនេះ*

## ការឃ្លាំមើល EITI



*រូបភាព: កិច្ចពិភាក្សាអំពី EITI រៀបចំដោយក្រុមថវិកាជាតិ (NBG) នៅខែឧសភា ឆ្នាំ ២០០៨។ រូបភាពដោយ Open Society Institute នៃប្រទេសអាស៊ែរបៃហ្សង់*

សម្ព័ន្ធភាពអង្គការមិនមែនរដ្ឋាភិបាលដើម្បីលើកស្ទួយតម្លាភាពនៅក្នុងឧស្សាហកម្មនិស្សារណៈ (សម្ព័ន្ធភាពអង្គការមិនមែនរដ្ឋាភិបាល) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៤ ដើម្បី តំណាងឱ្យសង្គមស៊ីវិលក្នុងការរៀបចំការឃ្លាំមើល និងការវាយតម្លៃការអនុវត្ត EITI។ សម្ព័ន្ធភាពអង្គការមិនមែនរដ្ឋាភិបាល បានចាប់ផ្តើមជាមួយសមាជិកចំនួន ៣២ ហើយនៅបច្ចុប្បន្ននេះ មានសមាជិកជាង ១១០។ សម្ព័ន្ធភាពនេះមានគោលបំណងពង្រឹងការសម្របសម្រួលបង្កើនការយល់ដឹង និងធ្វើការងារតស៊ូមតិដើម្បីឱ្យមានការយល់ដឹង និងការតាមដានសាធារណៈកាន់តែប្រសើរឡើងលើចំណូលធនធានជាពិសេសតាមរយៈរបាយការណ៍ EITI។ កិច្ចដំណើរការរបាយការណ៍ រួមមានសវនករអន្តរជាតិឯករាជ្យមួយ (ដែលត្រូវបានជ្រើសរើសដោយក្រុមការងារត្រីភាគីមួយ) ដែលវាយតម្លៃលើការបង់ប្រាក់របស់ក្រុមហ៊ុន ប្រៀបធៀបទៅនឹងព័ត៌មានបង់ប្រាក់ដែលផ្តល់ដោយរដ្ឋាភិបាល។ ក្រោយពេល

បញ្ចប់របាយការណ៍មួយ របស់សវនករឯករាជ្យត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ សម្ព័ន្ធភាព ពិនិត្យមើល និងទិតៀនរបាយការណ៍ទាំងនេះ និងផ្សព្វផ្សាយព័ត៌មានអំពីផលប៉ះពាល់នៃការគ្រប់គ្រងប្រាក់ចំណូលជូនសង្គមទាំងមូល ។ សម្ព័ន្ធភាព មានភាពជាតំណាងនៅក្នុងក្រុមការងារត្រីភាគី EITI ។

*EITI: http://www.eiti-az.org/ts_gen/eng/index.php អនុស្សរណៈនៃការយោគយល់*
*នៃសម្ព័ន្ធភាព អង្គការមិនមែនរដ្ឋាភិបាលមានដាក់ជូននៅក្នុងឧបសម្ព័ន្ធ G នៅក្នុងស៊ីឌីភ្ជាប់ជាមួយនេះ*
*សមាជិកនៃសម្ព័ន្ធភាពអង្គការមិនមែនរដ្ឋាភិបាលមានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ I នៅក្នុងស៊ីឌីភ្ជាប់ជាមួយនេះ*

### សមត្ថភាពរបស់សម្ព័ន្ធភាព

សម្ព័ន្ធភាពមានសមត្ថភាពបច្ចេកទេសល្អរួមជាមួយជំនាញនៅក្នុងវិស័យសេដ្ឋកិច្ច ការគ្រប់គ្រងថវិកា និងកំណែទម្រង់គោលនយោបាយ និងបទពិសោធន៍រយៈពេលវែងនៅក្នុងវិស័យប្រេងកាត ។ វិទ្យាស្ថានសង្គមបើកទូលាយ (Open Society Institute (OSI)) មុនពេលអនុវត្ត EITI បានបង្កើតក្រុមការងារនានាដែលរួមមានតំណាងសង្គមស៊ីវិលមួយចំនួន ។ ក្រុមការងារទាំងនេះបានពិនិត្យមើលបញ្ហានានាទាក់ទិននឹងវិស័យប្រេងកាត រួមមាន កិច្ចសន្យាប្រេង មូលនិធិប្រេងកាត និងគំនិតផ្តួចផ្តើមគោលនយោបាយនានា) និងបានធ្វើការតស៊ូមតិដើម្បីតម្លាភាពកាន់តែច្រើន និងការត្រួតពិនិត្យសាធារណៈលើការគ្រប់គ្រងប្រាក់ចំណូលប្រេងកាត ។ សម្ព័ន្ធភាពនៅក្នុងប្រទេសអាស៊ែប៊ែហ្សង់ក៏ហាក់បីដូចជាមានការសម្របសម្រួលគ្នាសមល្មមផងដែរនៅក្នុងការកំណត់និងធ្វើសកម្មភាពរបស់ខ្លួន និងមានទំនាក់ទំនងរឹងមាំជាមួយបណ្តាញជាតិ និងអន្តរជាតិ ថ្វីបើការផ្សារភ្ជាប់ការងាររបស់ពួកគេទៅនឹងកម្រិតមូលដ្ឋាននៅមានលក្ខណៈទន់ខ្សោយក្តី ។

លេខាធិការដ្ឋាន EITI អន្តរជាតិផ្តល់ការជួយគាំទ្រដល់សម្ព័ន្ធភាពអង្គការមិនមែនរដ្ឋាភិបាលទន្ទឹមគ្នានឹងក្រុមអន្តរជាតិសំខាន់ៗផ្សេងទៀតផងដែរ ដូចជាសម្ព័ន្ធភាពចេញផ្សាយអ្វីដែលអ្នកបានបង់ប្រាក់ (PWYP), CAFOD, អុកស្វាម (Oxfam), OSI និងអង្គការតម្លាភាពអន្តរជាតិ (Transparency International) ។ EITI នៅក្នុងប្រទេសអាស៊ែប៊ែហ្សង់ទទួលហិរញ្ញប្បទានមួយផ្នែកពីមូលនិធិក្នុងអាណត្តិព្យាបាលភាពម្ចាស់ជំនួយចម្រុះ (ដែលត្រូវបានគ្រប់គ្រងដោយធនាគារពិភពលោក) ។

## វិធីសាស្ត្រនៃការពាក់ព័ន្ធ

### ជាមួយសង្គមស៊ីវិល

សម្ព័ន្ធភាពដើម្បីលើកស្ទួយគណនេយ្យភាព និងតម្លាភាពនៃចំណូលធនធាននៅក្នុងប្រទេស

អាហ្វ្រិកបែហ្សង់ សុទ្ធសឹងមានសមត្ថភាពបច្ចេកទេសខ្ពស់ និងមានធនធានគ្រប់គ្រាន់ ។ ពួកគេបានផ្សារភ្ជាប់ខ្លួនយ៉ាងរឹងមាំជាមួយបណ្ដាញគាំទ្រដើម្បីជំនួយបច្ចេកទេស និងធនធាននៃគ្រឹះស្ថានហិរញ្ញវត្ថុអន្ដរជាតិធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្ដរជាតិ) ម្ចាស់ជំនួយ (Norad, Dfid, USAID) និងអង្គការមិនមែនរដ្ឋាភិបាលអន្ដរជាតិ (PWYP, OSI, RWI, Oxfam, TI) ។ ពួកគេផ្ដល់ការគាំទ្រ និងការចូលរួមជាមួយក្រុមសង្គមស៊ីវិលផ្សេងទៀតនៅក្នុងប្រទេស ជាពិសេស ក្រុមសង្គមស៊ីវិលទាំងឡាយដែលចូលរួមក្នុងគម្រោងសាជីវកម្ម) និងចូលរួមយ៉ាងមានអត្ថន័យជាមួយរដ្ឋាភិបាល និងសាជីវកម្មប្រេងកាត ។ ភារកិច្ចធំៗមួយចំនួននៃការផ្សៀងផ្ទាត់ព័ត៌មានដើម្បីអត្ថប្រយោជន៍របស់ក្រុមសង្គមស៊ីវិលជាគ្នីគ្នានិងសាធារណជនជារួម រួមមាន៖ ភាពជាតំណាងចំពោះរដ្ឋាភិបាល និងសាជីវកម្ម ការផ្សព្វផ្សាយព័ត៌មាន ការពាក់ព័ន្ធជាមួយប្រព័ន្ធ/បណ្ដាញសារព័ត៌មាន ការកសាងបណ្ដាញ និងទទួលបានការគាំទ្រអន្ដរជាតិ ។ ប៉ុន្ដែការលំបាកចម្បងនៃការងារនេះភាគច្រើនគឺការខ្វះខាតធនធាន ។

## ការផ្សព្វផ្សាយព័ត៌មាន

មធ្យោបាយមួយដ៏មានប្រសិទ្ធិភាពបំផុត និងដែលត្រូវបានប្រើយ៉ាងទូលាយដោយសម្ព័ន្ធភាពដើម្បីផ្សព្វផ្សាយព័ត៌មាន គឺគេហទំព័ររបស់ពួកគេ ។ ទស្សនៈទូទៅ គឺថាគេហទំព័រទាំងនេះ គឺមានប្រសិទ្ធិភាពក្នុងការជម្រុញការបោះពុម្ពផ្សាយសកម្មភាពរបស់សង្គមស៊ីវិលព្រឹត្តិការណ៍នានា និងការវិភាគរបាយការណ៍ និងបញ្ហាប្រាក់ចំណូល ។ សម្ព័ន្ធភាពរកឃើញថាគេហទំព័របង្កើនលទ្ធភាពទទួលបានព័ត៌មាន និងទាក់ទាញចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធទាំងអស់ (រួមទាំងរដ្ឋាភិបាលផងដែរ) ។ បន្ដិចម្ដងៗ ពួកគេ កំពុងផ្ដល់ការប្រុងប្រយ័ត្នដល់ការប្រើពាក្យសម្ដី និងទម្រង់ឱ្យបានសមស្របដើម្បីឈោងដល់អ្នកស្ដាប់ឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។

## ប្រព័ន្ធសារព័ត៌មាន

ការបង្កើត និងការថែរក្សាទំនាក់ទំនងការងារជាប់លាប់ជាមួយប្រព័ន្ធសារព័ត៌មាន (អ្នកសារព័ត៌មាន) គឺសំខាន់ក្រៃលែងដើម្បីជម្រុញការយល់ដឹង និងការពិភាក្សាសាធារណៈ ។ ជាញឹកញាប់ ប្រការនេះដាក់សម្ពាធគ្រប់គ្រាន់លើរដ្ឋាភិបាល (និងក្រុមហ៊ុន) ឱ្យដោះស្រាយការបារម្ភរបស់សង្គមស៊ីវិល ។ វាក៏កែលម្អផងដែរនូវការយកចិត្តទុកដាក់ និងការយល់ដឹងរបស់អ្នកសារព័ត៌មានអំពីបញ្ហានានាទាក់ទិននឹងការប្រមូល និងការប្រើប្រាស់ប្រាក់ចំណូលប្រេងកាត ។ ព័ត៌មានដែលផ្ដល់ជូនអ្នកសារព័ត៌មានចាំបាច់ត្រូវមានទម្រង់ (និងភាសា) ដែលអាចយល់បាន ។ ប្រការនេះ គឺជាបញ្ហាមួយ ដោយសារជាទូទៅសមត្ថ-ភាពបច្ចេកទេសរបស់អ្នកសារព័ត៌មានគឺមានកម្រិត ។

ទោះបីជាគេឃើញមានស្នាដៃគួរសមរបស់ប្រព័ន្ធសារព័ត៌មាន ក្នុងការជម្រុញការយល់ដឹង

សាធារណៈអំពីការប្រមូល និងការគ្រប់គ្រងចំណូលប្រេងកាតនៅក្នុងប្រទេសអាហ្សែបៃហ្សង់ក្ដី ក៏គេឃើញមានព្រំដែនលើអ្វីដែលប្រព័ន្ធសារព័ត៌មានអាចផ្សព្វផ្សាយ ។ តាមទ្រឹស្ដី ប្រព័ន្ធសារព័ត៌មានមានសេរីភាពក្នុងការនិយាយស្ដី (ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ) ប៉ុន្តែ តាមការពិតជាក់ស្ដែងរដ្ឋាភិបាលពិតជាដាក់កំហិតលើសេរីភាពនៃការនិយាយស្ដី និងសេរីភាពរបស់សារព័ត៌មាន ។

## ការកសាងបណ្ដាញ

ថ្វីបើ ការកសាងបណ្ដាញកំពុងតែមានកម្លាំងកាន់តែខ្លាំងឡើងក្ដី ក៏គេឃើញមានការយល់ឃើញជាក់ស្ដែងនៅក្នុងប្រទេសអាហ្សែបៃហ្សង់ថា តំបន់នានានៅក្រៅរដ្ឋធានី និងទីរួមខេត្តមិនសូវបានចូល-រួម និងមិនសូវមានលទ្ធភាពទទួលបានព័ត៌មានទេ ។ សម្ព័ន្ធភាពក្រៅប្រព័ន្ធកំពុងរីកលូតលាស់រវាងក្រុមក្នុងមូលដ្ឋានដែលមានបទពិសោធន៍ច្រើនជាងនៅកម្រិតសហគមន៍ និងក្រុមទាំងឡាយនៅតាមទីក្រុងដែលមានជំនាញបច្ចេកទេសឃ្លាំមើល ។ ចលនានេះកំពុងនាំឱ្យមានការចូលរួមកាន់តែមានប្រសិទ្ធិភាពរឹងមាំឡើង និងផ្ដល់ជូនរដ្ឋាភិបាលនូវជម្រើសនានាដែលអាចអនុវត្តបាន និងមានប្រសិទ្ធភាពនៅក្នុងវិស័យសំខាន់ៗនៃចំណាយសាធារណៈដូចដែលមានកំណត់នៅក្នុងថវិការដ្ឋ ។

## ការគាំទ្រ/ភាពជាដៃគូអន្តរជាតិ

កត្តានាំមុខដ៏សំខាន់មួយដើម្បីឱ្យរដ្ឋាភិបាលនៃប្រទេសអាហ្សែបៃហ្សង់ពាក់ព័ន្ធជាមួយ និងព្យាយាមឆ្លើយតបទៅនឹងការបារម្ភរបស់សង្គមស៊ីវិល គឺសម្ពាធនិងការពិនិត្យពិច័យអន្តរជាតិតាមរយៈគំនិតផ្ដួចផ្ដើមពិភពលោកនានា ដូចជា EITI ជាដើម ។ម្យ៉ាងទៀត អង្គការមិនមែនរដ្ឋាភិបាល និងចលនា អន្តរជាតិនានាដែលមានកេរ្ដិ៍ឈ្មោះល្អ ដូចជា PWYP, OSI, RWI, TI, និង អុកស្វាម (Oxfam) ក៏ផ្ដល់ផងដែរនូវការគាំទ្រនិងធនធាន ។ ក្រុមដែលមានប្រសិទ្ធភាពជាងគេនៅក្នុងប្រទេសអាហ្សែបៃហ្សង់ បានទទួលការគាំទ្រដ៏រឹងមាំពីអ្នកផ្ដល់ជំនួយធំៗ ដូចជាទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID), គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និងក្រុមហ៊ុនឯកជន ដូចជា BP ជាដើម ។

## កង្វះខាតធនធាននិង/ឬជំនាញ

ជារួមសម្ព័ន្ធភាពធំៗ និងដៃគូរបស់ពួកគេមានសមត្ថភាពបច្ចេកទេសមាំមួន ។ ប៉ុន្តែ ចំណុចនេះគឺមិនដូចគ្នាទេនៅកម្រិតមូលដ្ឋានដោយសារការកសាងបណ្ដាញទន់ខ្សោយ និងមជ្ឈការនៃការងារតម្លាភាពចំណូលធនធាន ។ សម្ព័ន្ធភាពធំទាំងពីរមានលក្ខណៈសម្របសម្រួលគ្នាបានល្អប្រសើរ និងទទួលបានការគាំទ្រច្រើនពីអង្គការអន្តរជាតិ ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមានការលំបាកក្នុងការស្វែងរកធនធាន និងខ្វះការសម្របសម្រួលរួមដែលនាំឱ្យមានសកម្មភាពត្រួតគ្នា ។

# ជាមួយរដ្ឋាភិបាល

## អភិវឌ្ឍទំនាក់ទំនងការងារល្អ

ការកសាងទំនាក់ទំនងការងារដែលអាចទុកចិត្តគ្នាជាមួយមន្ត្រីពាក់ព័ន្ធនៅក្នុងវិស័យសាធារណៈ (និងនៅក្នុងវិស័យផ្សេងទៀត) គឺសំខាន់ខ្លាំងណាស់នៅក្នុងប្រទេសអាស៊ែប៊ែហ្សង់។ សម្ព័ន្ធភាព និង សមាជិកដែលមានបទពិសោធន៍ច្រើនក្នុងការឃ្លាំមើលថវិកាក្នុងគម្រោងសាធារណៈផ្សេងៗ បានកសាង ទំនាក់ទំនងការងារជិតស្និទ្ធជាមួយមន្ត្រីរដ្ឋាភិបាលមួយចំនួន។ ការងារតស៊ូមតិប្រកបដោយប្រសិទ្ធភាព សំដៅលើរដ្ឋាភិបាលដើម្បីលើកស្ទួយតម្លាភាពក្នុងការគ្រប់គ្រងចំណូលធនធាន ពឹងផ្អែកយ៉ាងច្រើនលើ ជំនាញ និងចំណេះដឹងបច្ចេកទេសអំពីវិស័យនេះរបស់សមាជិកសម្ព័ន្ធភាព។ ជំនាញបច្ចេកទេសដ៏មាំមួនពី សង្គមស៊ីវិល (គួបផ្សំជាមួយបណ្តាញរឹងមាំជាមួយមន្ត្រីរដ្ឋាភិបាល) នាំមកនូវអត្ថប្រយោជន៍ទៅវិញទៅ មកសម្រាប់ភាគីទាំងសងខាង។ មន្ត្រីនានាត្រូវបានផ្តល់ជូននូវការវិភាគដែលផ្អែកលើភស្តុតាង ខណៈដែល សង្គមស៊ីវិលកាន់តែមានឱកាសទទួលបានព័ត៌មានផ្លូវការ ដែលមិនសុទ្ធតែអាចរកបានជាសាធារណៈ ឡើយ។

## កំណែទម្រង់រចនាសម្ព័ន្ធ

ថ្វីបើ ច្បាប់គតិយុត្តិត្រូវបានចាត់ទុកថាមានបទដ្ឋានខ្ពស់ក្តី ក៏ជាទូទៅ ខ្វះខាតនៃតម្លាភាព និង គណនេយ្យភាព ធ្វើឱ្យគេមានការលំបាកក្នុងការឃ្លាំមើលប្រសិទ្ធិភាពនៃច្បាប់។ តាមទស្សនៈរបស់សង្គម ស៊ីវិល ទោះបីជាមានច្បាប់ល្អក្តី ក៏អសមត្ថភាព ឬការគ្មានឆន្ទៈរបស់រដ្ឋាភិបាល ក្នុងការអនុវត្តច្បាប់ ធ្វើឱ្យសង្គមស៊ីវិលមានការពិបាកក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធិភាពទៅនឹងបញ្ហាទាំងឡាយ ទាក់ទិននឹងសង្គមជារួមដែរ។ ឧទាហរណ៍មួយគឺលទ្ធភាពទទួលព័ត៌មាន។ ទោះបីជា សិទ្ធិទទួលព័ត៌មាន (FOI) មានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសអាស៊ែប៊ែហ្សង់ក្តី ក៏តំណាងសង្គមស៊ីវិល ត្រូវបានគេ បដិសេធមិនផ្តល់ព័ត៌មានម្តងហើយម្តងទៀត (ជាពិសេសព័ត៌មានអំពីចំណាយសាធារណៈ)។ ឧទាហរណ៍ មួយទៀត គឺគណនេយ្យភាពស្ថាប័នសាធារណៈ។ ការគ្រប់គ្រង SOFAZ ត្រូវបានអនុម័តតាមរយៈ ក្រឹត្យរបស់ប្រធានាធិបតី ប៉ុន្តែរដ្ឋសភាត្រូវបានគេយល់ឃើញថាទន់ខ្សោយខ្លាំង នៅក្នុងប្រទេស អាស៊ែប៊ែហ្សង់ បានជាមិនហ៊ានតវ៉ាសេចក្តីសម្រេចចិត្តមិនសមស្របណាមួយទេ។

នៅតាមប្រទេសទាំងឡាយដូចជាប្រទេសអាស៊ែប៊ែហ្សង់ ដែលស្ថិតក្រោមឥទ្ធិពលនៃចំណូល ប្រេងកាត គេចាំបាច់ត្រូវពិចារណាកំណែទម្រង់រចនាសម្ព័ន្ធដើម្បីយន្តការអភិបាលកិច្ចល្អឱ្យបានទូលាយ ជាង ដើម្បីដាក់បញ្ចូលកិច្ចដំណើរការគ្រប់គ្រងវិស័យសាធារណៈ បរិយាកាសអាជីវកម្មនិងវិនិយោគ និង គោលនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ច។ គេឃើញមានកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធខ្លះដែលយក

ចិត្តទុកដាក់ដោយផ្ទាល់លើវិស័យប្រេងកាត ខណៈដែលកម្មវិធីផ្សេងទៀតមានផលប៉ះពាល់ប្រយោលលើវិស័យប្រេងកាត តាមរយៈការកែលម្អទូទៅនូវយន្តការតម្លាភាព និងអភិបាលកិច្ច ។ កម្មវិធីមួយចំនួនត្រូវបានជួយឧបត្ថម្ភដោយគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និងម្ចាស់ជំនួយ ដូចជា ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារអឺរ៉ុបដើម្បីស្តារ និងអភិវឌ្ឍន៍ (EBRD) សហភាពអឺរ៉ុប (EU) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) អុកស្វាម Oxfam (ចក្រភពអង់គ្លេស និង Novib) មូលនិធិអឺរ៉ុបអាស៊ី រដ្ឋាភិបាលណ័រវេ រដ្ឋាភិបាលចក្រភពអង់គ្លេស និងវិទ្យាស្ថានសង្គមបើកទូលាយ (OSI) ។

## ឆន្ទៈនយោបាយ

ឆន្ទៈនយោបាយចំពោះកំណែទម្រង់ដើម្បីគណនេយ្យភាព និងតម្លាភាពនៃចំណូលសាធារណៈមានលក្ខណៈចម្រុះនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ។ គេឃើញមានឆន្ទៈនយោបាយគួរសមក្នុងការអនុវត្តកិច្ចដំណើរការ EITI ដោយមានមន្ត្រីរដ្ឋាភិបាលសំខាន់ៗនាំមុខកិច្ចដំណើរការអនុវត្តនេះ ។ ប៉ុន្តែឆន្ទៈនយោបាយក្នុងការកែលម្អយ៉ាងពិតប្រាកដនូវការអនុវត្តអភិបាលកិច្ចល្អ នៅក្នុងទូទាំងនីតិវិធីរដ្ឋបាលនៃវិស័យសាធារណៈ (រួមទាំងការគ្រប់គ្រងចំណាយសាធារណៈផងដែរ) គឺទន់ខ្សោយ ។ ក្នុងបរិបទនេះសង្គមស៊ីវិលជួបការលំបាកក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាព និងមានឥទ្ធិពលលើឥរិយាបថរបស់រដ្ឋាភិបាល ។ សមត្ថភាពរបស់សង្គមស៊ីវិលគឺរឹងមាំ ហើយពួកគេដោះស្រាយបញ្ហាតម្លាភាពប្រេងកាត ក្នុងលក្ខណៈវិជ្ជាជីវៈ និងសម្របសម្រួលគ្នា ។ ប៉ុន្តែ រដ្ឋាភិបាលមិនចាត់ទុកតួនាទីរបស់សង្គមស៊ីវិលថាជាដៃគូសហការគ្នាឡើយ ។ ផ្ទុយទៅវិញ គេឃើញមានការវិវឌ្ឍនៃទំនាក់ទំនងបដិបក្ខរវាងក្រុមទាំងពីរនេះ ។

# ជាមួយសាជីវកម្ម

## ពាក់ព័ន្ធជាមួយផ្នែកឯកជន

គេឃើញមានក្រុមហ៊ុនឯកជនជាច្រើនដែលដំណើរការនៅក្នុងវិស័យឧស្សាហកម្មនិស្សារណកម្មនៅប្រទេសអាហ្វ្រិកខាងត្បូង និងការប្រាថ្នាកាន់តែកើនឡើងចង់ឱ្យក្រុមហ៊ុនធ្វើការក្នុងភាពជាដៃគូសហការគ្នាជាមួយក្រុមសង្គមស៊ីវិល ។ គេឃើញមានវិធីមួយចំនួន ដែលក្រុមហ៊ុនប្រេងកាតបានពាក់ព័ន្ធជាមួយសង្គមស៊ីវិលតាមរយៈកិច្ចដំណើរការអនុវត្ត EITI កម្មវិធីសហគមន៍ និងតួនាទីផ្តល់ប្រឹក្សា / តួនាទីឃ្លាំមើល ។

## *EITI*

សង្គមស៊ីវិលគឺជាផ្នែកមួយនៃក្រុមការងារត្រីភាគី និងការផលិតនិងការផ្សព្វផ្សាយរបាយការណ៍ EITI ។ ក្រុមហ៊ុនទានាបានផ្តល់ការគាំទ្រដល់សង្គមស៊ីវិលដើម្បីកែលម្អសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការអនុវត្ត EITI ។

## *កម្មវិធីតាមសហគមន៍*

ក្រុមហ៊ុនប្រេងកាតមួយចំនួនធ្វើការក្នុងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិដើម្បីអនុវត្តកម្មវិធីតាមសហគមន៍ ។

## *ក្រុមប្រឹក្សាអភិវឌ្ឍន៍តំបន់សមុទ្រកាសព្យៀន*

ការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍តំបន់សមុទ្រកាសព្យៀន (CDAP) ដោយមានការត្រួតពិនិត្យរបស់សង្គមស៊ីវិល (គំនិតផ្តួចផ្តើមមួយរបស់ក្រុមហ៊ុន BP) បានផ្តល់ការពិនិត្យពិច័យលើផលប៉ះពាល់របស់ក្រុមហ៊ុនលើសហគមន៍ក្នុងមូលដ្ឋាន ។ CDAP ផ្តល់អនុសាសន៍ជូនក្រុមហ៊ុន BP អំពីការកែលម្អលទ្ធផលខាងសង្គមកិច្ច សេដ្ឋកិច្ច និងបរិស្ថាន ។

## *គម្រោងឃ្លាំមើល BP- OSI*

ជាកិច្ចប្រឹងប្រែងមួយដើម្បីពាក់ព័ន្ធជាមួយសង្គមស៊ីវិល និងដើម្បីកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិល ក្រុមហ៊ុន BP និង OSI បានបណ្តុះបណ្តាលអង្គការមិនមែនរដ្ឋាភិបាលស្តីពីបច្ចេកទេសឃ្លាំមើល និងបច្ចេកទេសធ្វើសវនកម្ម ។

## ប្រសិទ្ធិភាពរបស់អង្គការមិនមែនរដ្ឋាភិបាលលើការធ្វើអាជីវកម្ម

ចំពោះកម្រិតដែលសង្គមស៊ីវិលបានមានឥទ្ធិពលជាវិជ្ជមានលើក្រុមហ៊ុនឱ្យប្រកាន់យកការអនុវត្តកាន់តែល្អប្រសើរឡើង ភាគច្រើនគេយល់ថាវាគឺជាការប្រឹងប្រែងរួមរវាងអង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ។ គេឃើញមានចំណុចបារម្ភមួយចំនួនអំពីការសហការជាមួយក្រុមហ៊ុន ដូចជាកង្វះខាតការយកចិត្តទុកដាក់លើសកម្មភាពមិនជាក់ស្តែងមួយចំនួន (ដូចជា ការងារតស៊ូមតិជាដើម) ។ ក្រុមហ៊ុនគាំទ្រ តែការងារណាដែលមិនធ្វើឱ្យរដ្ឋាភិបាលអន់ចិត្តប៉ុណ្ណោះ ។ ម្យ៉ាងទៀត តំណាងសង្គមស៊ីវិលអាចត្រូវបាន មើលឃើញថាជាសាខារបស់ក្រុមហ៊ុន និងត្រូវបានចាត់ទុកថាខ្វះឯករាជ្យភាព ។ ទោះជាយ៉ាងណាក្តីក៏ កិច្ចសហប្រតិបត្តិការទាំងនេះភាគច្រើនត្រូវបានគេមើលឃើញក្នុងទស្សនៈវិជ្ជមានដែលជួយកសាងការពិភាក្សាកាន់តែមាំមួនឡើងរវាងសង្គមស៊ីវិល និងក្រុមហ៊ុនឯកជន ។

# ប្រទេសទីម័រឡេស្តេ

## សាវតា

| | |
|---|---|
| **ចំនួនប្រជាជន ៖** | ១.០៨៤.៩៧១ |
| **សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ៖** | ១៥០ , ១៧៧ |
| **ជីវិតរំពឹង ៖** | ៦៦.៦ ឆ្នាំ |
| **ចំនួនប្រជាជនក្រោមបន្ទាត់ក្រីក្រ ៖** | ៤២% |
| **ផលិតផលក្នុងស្រុកសរុប-ក្នុងប្រជាជនម្នាក់ (PPP)៖** | ២.000 ដុល្លារ |
| **ប្រេងកាត - ផលិតកម្ម ៖** | ៩៤.៤២០ ធុង / ថ្ងៃ |
| **ឧស្ម័នធម្មជាតិ - ផលិតកម្ម ៖** | មិនមានទិន្នន័យ |
| **ចំណូលពីប្រេងកាតនិងឧស្ម័ន ៖** | ៤៩២ លានដុល្លារ (២០០៦) |

នាំចេញ៖ ទំនិញ - កាហ្វេ ខ្លឹមចន្ទន៍ ថ្មម៉ាប សក្តានុពលខ្ពស់សម្រាប់ ការនាំចេញប្រេងកាត និងវ៉ានីយ៉ (vanilla)




*ប្រភព៖ សៀវភៅព័ត៌មានពិភពលោក (The World Factbook)*[3]

*http:// www.cia.gov/library/publications/the-world-factbook/geos/tt.html*

## ទីម័រឡេស្តេ

ប្រទេសទីម័រឡេស្តេគឺជាប្រទេសក្រីក្រតូចមួយពឹងផ្អែកលើប្រេងកាត ដែលទើបតែងើបចេញពីអស្ថេរភាពច្រើនឆ្នាំ ជាមួយប្រជាជនចំនួនពាក់កណ្តាលរស់នៅក្រោមបន្ទាត់ក្រីក្រ ហើយប្រជាជននៅតាមជនបទពីរភាគបីពឹងអាស្រ័យលើកសិកម្ម ដោយមានកាហ្វេជាដំណាំសំខាន់សម្រាប់លក់ ។ ប្រទេសនេះពឹងផ្អែកយ៉ាងខ្លាំងលើជំនួយបរទេសសម្រាប់កសាង និងធ្វើឱ្យប្រទេសជាតិមានស្ថេរភាព ខណៈដែលកោលាហលស៊ីវិលនៅមានជាបន្ត ។ ប៉ុន្តែ គេឃើញមានជោគជ័យខ្លះៗនៅក្នុងការជំនះការលំបាកផ្នែកអភិវឌ្ឍន៍ចាប់តាំងពីទទួលបានឯករាជ្យក្នុងឆ្នាំ ២០០២ ដោយប្រើភោគទ្រព្យប្រេងកាតក្នុងសមុទ្រ ដើម្បីជម្រុញកំណើន និងកាត់បន្ថយភាពក្រីក្រ ។ ថ្មីៗនេះ លំហូរចូលប្រាក់ចំណូលច្រើនដែលត្រូវបានបង្កើនឡើងដោយតម្លៃពិភពលោកខ្ពស់ និងចំណែកស្មួយសារជាមួយប្រទេសអូស្ត្រាលី បានបង្កើន តម្លៃនៃមូលនិធិប្រេងកាតជាតិទៅដល់ប្រហែល ១,០ ពាន់លានដុល្លារ ជាមួយនឹងកំណើន ៨០ លានដុល្លារក្នុងមួយខែ ។ មូលនិធិប្រេងកាតនេះត្រូវបានគ្រប់គ្រងប្រកបដោយតម្លាភាព ដែលត្រូវទទួលការធ្វើ សវនកម្មឯករាជ្យ និងត្រូវបានដាក់បញ្ចូលទៅក្នុងថវិការដ្ឋាភិបាលដើម្បីទ្រទ្រង់ចំណាយសាធារណៈ ។

មុខព្រួញនៃចំណាយសាធារណៈ រួមមានវិស័យដឹកជញ្ជូន សុខាភិបាល អបរំ និងការផលិតអគ្គិសនី ។ ថ្វីបើ កំណើនប្រាក់ចំណូលលើសពីការប៉ាន់ស្មានថវិកាក្តី ក៏ចំណាយរដ្ឋាភិបាលមានការខ្វះខាតដែរ ដោយសារការអនុវត្តថវិកាទន់ខ្សោយ ។ កំណើនចាំបាច់ត្រូវបង្កើនល្បឿនយ៉ាងលឿនដើម្បីកាត់បន្ថយភាពក្រីក្រ ។ ជាលទ្ធផល ប្រការនេះតម្រូវឱ្យមានកំណើនច្រើននៅក្នុងវិនិយោគឯកជនលើវិស័យកសិកម្ម ជលផល និងទេសចរណ៍ ដែលត្រូវបានបំពេញបន្ថែមដោយការអនុវត្តគម្រោងវិនិយោគសាធារណៈកាន់តែប្រសើរឡើងនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល និងអប់រំ ។ ប៉ុន្តែ គេឃើញមានកង្វះខាតសមត្ថភាពដ៏ធ្ងន់ធ្ងរដើម្បីអនុវត្តគម្រោង និងលើកទឹកចិត្តវិនិយោគឯកជន ។ ប្រទេសនេះ ជាប់ចំណាត់ថ្នាក់បាតក្រោមគេទីពីរនៅក្នុងចំណោមប្រទេសចំនួន ១៧៥ នៅក្នុងសូចនាករធ្វើអាជីវកម្មរបស់ធនាគារពិភពលោក ។

បញ្ហាប្រឈមចំពោះមុខប្រទេសទីម័រឡេស្តេ គឺការធានាឱ្យបាននូវស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ។ កិច្ចអភិវឌ្ឍន៍រយៈពេលវែងប្រឈមមុខនឹងភារកិច្ចធំៗចំនួនបីៈ ភារកិច្ចទីមួយគឺការធានាឱ្យបានថាភោគទ្រព្យប្រេងកាតត្រូវបានគ្រប់គ្រងដើម្បីផលប្រយោជន៍មនុស្សជំនាន់ក្រោយ ទន្ទឹមគ្នានឹងការគាំទ្រវិនិយោគបច្ចុប្បន្នលើការអភិវឌ្ឍសង្គមកិច្ច និងសេដ្ឋកិច្ចដ៏សំខាន់, ភារកិច្ចទីពីរគឺការបង្កើនសមត្ថភាពរដ្ឋាភិបាលក្នុងការគ្រប់គ្រងសេដ្ឋកិច្ច ដើម្បីធានាឱ្យបាននូវការរៀបចំថវិកានិងចំណាយឱ្យបាន ល្អ និងភារកិច្ចទីបីគឺការលើកទឹកចិត្តវិនិយោគឯកជនដោយកាត់បន្ថយចំណាយនៃការធ្វើអាជីវកម្ម ។

*ព័ត៌មានស្តីពីទីម័រខាងកើត: http://www.adb.org/Documents/Books/ADO/2007/TIM.asp*

# បញ្ហាសំខាន់ៗ

បញ្ហាគន្លឹះជាក់លាក់ដែលកំណត់ប្រភេទនៃសម្ព័ន្ធភាពនៅក្នុងប្រទេសទីម័រឡេស្តេ គឺដូចគ្នានឹងប្រទេសអាហ្សែរបៃហ្សង់ដែរៈ ការគ្រប់គ្រងមូលនិធិប្រេងកាត និងកិច្ចដំណើរការអនុវត្ត EITI ។

## មូលនិធិប្រេងកាត

មូលនិធិប្រេងកាតទីម័រឡេស្តេ (TLPF) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៥ ។ មូលនិធិនេះ គឺផ្អែកលើ ‘គម្រូប្រទេសណ័រវេ’ ។ នីតិវិធីចាត់ចែង និងប្រតិបត្តិការនៃមូលនិធិប្រេងកាតទីម័រឡេស្តេ ត្រូវបានគ្រប់គ្រងដោយច្បាប់មូលនិធិប្រេងកាត ។ ច្បាប់នេះត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់សាធារណៈច្រើន និងត្រូវបានអនុម័តដោយរដ្ឋសភាទីម័រឡេស្តេ ។ មូលនិធិប្រេងកាតទីម័រឡេស្តេមានប្រព័ន្ធតុល្យភាពអំណាចសម្រាប់ការត្រួតពិនិត្យ និងការរាយការណ៍ ដោយតម្រូវឱ្យមានធាតុចូលពីស្ថាប័នផ្សេងៗមួយចំនួនរួមមាន ក្រុមប្រឹក្សាពិគ្រោះយោបល់ជាមួយនឹងភាពជាតំណាងរបស់សង្គមស៊ីវិល) រួមគ្នា ។ ស្ថាប័នទាំងនេះបង្កើនភាពជឿជាក់ថា ប្រាក់ចំណូលពីមូលនិធិប្រេងកាតទីម័រឡេស្តេ ត្រូវបានប្រើស្របតាមច្បាប់មូលនិធិប្រេងកាត និងរដ្ឋសភា (ដែលអនុម័តការផ្ទេរប្រាក់ចេញពីមូលនិធិប្រេងកាតទីម័រឡេស្តេ) ។ ក្រោយពេលទទួលបានការឯកភាព ប្រាក់ផ្ទេរពីមូលនិធិប្រេងកាតទីម័រឡេស្តេអាចត្រូវបានចាយតែតាមរយៈថវិការដ្ឋាភិបាលប៉ុណ្ណោះ ។ វិធានដែលគ្រប់គ្រងការប្រើប្រាក់ចំណូលនៃមូលនិធិប្រេងកាតទីម័រឡេស្តេ ក៏កំណត់ផងដែរនូវការដាក់កំហិតច្បាស់លាស់មួយដែលថារាល់ការដកប្រាក់ទាំងអស់មិនត្រូវបន្ថយចំណូលអចិន្ត្រៃយ៍ដែលអាចផ្តល់ចេញពីមូលនិធិឡើយ ។

ទស្សនៈសង្គមស៊ីវិលគឺមានលក្ខណៈវិជ្ជមានមធ្យមលើការគ្រប់គ្រងមូលនិធិប្រេងកាតទីម័រឡេស្តេ ដោយសារពួកគេមានតួនាទីស្របច្បាប់មួយក្នុងការត្រួតពិនិត្យមូលនិធិនេះ និងក្នុងស្ថាប័នគ្រប់គ្រង ក៏ដូចជាមានលទ្ធភាពទូលាយលើការឃ្លាំមើលវឌ្ឍនភាព ។ ប៉ុន្តែ គេទទួលស្គាល់ថាទាំងសង្គមស៊ីវិល ទាំងរដ្ឋាភិបាលសុទ្ធតែខ្វះជំនាញបច្ចេកទេសដើម្បីឃ្លាំមើលប្រកបដោយប្រសិទ្ធិភាព និងដើម្បីចូលរួមក្នុងកិច្ចដំណើរការនេះឱ្យបានពេញលេញ ។



*រូបភាពៈ ស្ថានីយ៍បូមប្រេងដោយ លូតា ហាមាទុក (Luta Hamatuk) ប្រទេស ទីម័រឡេស្តេ*

ក្នុងការរៀបចំមូលនិធិប្រេងកាតទីម័រឡេស្តេ ប្រទេសទីម័រឡេស្តេ ទទួលជំនួយពិសេសពីរដ្ឋាភិបាលណ័រវ៉េ ដោយសារមូលនិធិប្រេងកាតទីម័រឡេស្តេគឺស្រដៀងគ្នានឹងមូលនិធិប្រេងកាតរបស់ប្រទេសណ័រវ៉េ ។ ស្ថាប័នផ្សេងទៀតដែលកំពុងផ្តល់ជំនួយ រួមមានធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។

*ព័ត៌មានស្តីពីមូលនិធិប្រេងកាតទីម័រឡេស្តេ: http://www.laohamutuk.org/Oil/PetFund/05PFIndex.htm*
*ដើម្បីដឹងព័ត៌មានបន្ថែមអំពីមូលនិធិប្រេងកាតទីម័រឡេស្តេ សូមមើលឧបសម្ព័ន្ធ R, S, T នៅក្នុងស៊ីឌីភ្ជាប់ជាមួយនេះ*

## គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI)

ក្នុងឆ្នាំ ២០០២ នាយករដ្ឋមន្ត្រីអង់គ្លេសនៅពេលនោះ លោក តូនី ប្លែរ បានផ្តួចផ្តើម EITI (គំនិតផ្តួចផ្តើមស្ម័គ្រចិត្តមួយ) ។ កិច្ចដំណើរការពិភពលោកនៃ EITI បង្រួបបង្រួមសហព័ន្ធមួយនៃក្រុមហ៊ុន រដ្ឋាភិបាល វិនិយោគិន និងអង្គការសង្គមស៊ីវិលឱ្យធ្វើការដើម្បីតម្លាភាព និងគណនេយ្យភាពរដ្ឋាភិបាលកាន់តែច្រើនឡើង តាមរយៈការបញ្ចេញព័ត៌មានជាសាធារណៈកាន់តែប្រសើរឡើង និងការត្រួតពិនិត្យដោយឯករាជ្យលើប្រាក់ចំណូលប្រេងកាត ឧស្ម័ន និង រ៉ែ ។ លេខាធិការដ្ឋាន EITI ស្ថិតនៅក្រុងអូស្លូ ប្រទេសណ័រវ៉េ ។

ចំណុចសំខាន់មួយនៅក្នុងការអនុវត្ត EITI គឺការចូលរួមរបស់សមាជិកឯករាជ្យរបស់សង្គមស៊ីវិល ។ លក្ខណៈវិនិច្ឆ័យ EITI ទីប្រាំចែងថា: សង្គមស៊ីវិលចូលរួមយ៉ាងសកម្មជាអ្នកចូលរួមមួយក្នុងការរៀបចំ ការឃ្លាំមើល និងការវាយតម្លៃលើកិច្ចដំណើរការនេះ និងរួមចំណែកដល់ការពិភាក្សាសាធារណៈ ។

ប្រទេសទីម័រឡេស្តេបានអនុម័ត EITI ក្នុងខែ មិថុនា ឆ្នាំ ២០០៣ ។ ថ្វីបើប្រទេសទីម័រឡេស្តេបានតាក់តែងច្បាប់សរសេរបានល្អដើម្បីពង្រឹងការប្រមូល និងការគ្រប់គ្រងប្រាក់ចំណូលប្រេងកាតរបស់ខ្លួនក្តី ក៏ការអនុវត្តកិច្ចដំណើរការ EITI របស់ខ្លួនមានលក្ខណៈយឺតដែរ ។ ក្រុមការងារត្រីភាគី EITI មួយ ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ២០០៦ ដើម្បីដឹកនាំការអនុវត្ត EITI នៅក្នុងប្រទេសទីម័រឡេស្តេ ។ ក្រុម នេះបានជួបប្រជុំលើកទីមួយក្នុងខែឧសភា ឆ្នាំ ២០០៧ ។

*EITI: www.eitransparency.org*
*គោលការណ៍និងលក្ខណៈវិនិច្ឆ័យ EITI មានលើកឡើងនៅក្នុងឧបសម្ព័ន្ធ H នៅក្នុងស៊ីឌីភ្ជាប់ជាមួយនេះ*

# សម្ព័ន្ធភាពសង្គមស៊ីវិល

## ការឃ្លាំមើលថវិកាជាតិ

ដោយសារប្រាក់ចំណូលរបស់ប្រទេសទីម័រឡេស្តេ ពឹងផ្អែកយ៉ាងច្រើនលើប្រាក់ចំណូលដែលបានមកពីប្រេងកាតនិងឧស្ម័ន សង្គមស៊ីវិលបានរៀបចំក្រុមមួយដើម្បីឃ្លាំមើលការគ្រប់គ្រងថវិការបស់រដ្ឋាភិបាល ។ ក្រុមស្នូលដើម្បីតម្លាភាព (CGT) ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ២០០៥ ។ ក្រុមស្នូលដើម្បីតម្លាភាពនេះតស៊ូមតិដើម្បីតម្លាភាព និងគណនេយ្យភាពសម្រាប់ចំណូលរដ្ឋាភិបាល និងរៀបចំថវិកា និងឃ្លាំមើលការអនុវត្តថវិការបស់ស្ថាប័នរដ្ឋាភិបាល ។ ក្រុមនេះ ក៏ជម្រុញការយល់ដឹងសហគមន៍ផងដែរ អំពីថវិកា និងចំណាយ ។

*សមាជិកនៃក្រុមស្នូលដើម្បីតម្លាភាពមានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ U នៅក្នុងស៊ីឌីភ្ជាប់ជាមួយនេះ ។*

## ការឃ្លាំមើល EITI

វេទិកាអង្គការមិនមែនរដ្ឋាភិបាលទីម័រឡេស្តេ (FONGTIL) ត្រូវបានបង្កើតឡើងនៅចុងទសវត្សរ៍ ១៩៩០ ដើម្បីជួយក្នុងការអភិវឌ្ឍនិងការសម្របសម្រួលសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ប៉ុន្តែ នៅពេលប៉ុន្មានឆ្នាំថ្មីៗនេះ FONGTIL បានបង្វែរការយកចិត្តទុកដាក់របស់ខ្លួនមួយចំនួនទៅលើបញ្ហានានាទាក់ទិននឹងការគ្រប់គ្រងប្រាក់ចំណូលប្រេងកាតប្រកបដោយតម្លាភាព ដោយខិតខំសម្របសម្រួល និងពង្រឹងការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងវិស័យនេះ ។ FONGTIL ផ្តល់ការត្រួតពិនិត្យប្រកបដោយការសម្របសម្រួលគ្នារបស់សង្គមស៊ីវិលលើកិច្ចដំណើរការអនុវត្ត EITI ក៏ដូចជាការមានភាពជាតំណាងនៅក្នុងក្រុមការងារត្រីភាគី EITI ។

*FONGTIL: http://www.geocities.com/etngoforum/kont.htm*

ទោះបីមិនមែនជាសម្ព័ន្ធភាពសង្គមស៊ីវិលមួយក្តី ក៏គេឃើញមានផងដែរនូវក្រុមប្រឹក្សាពិគ្រោះយោបល់មូលនិធិប្រេងកាត (PFCC) មួយដែលមានភាពជាតំណាងសង្គមស៊ីវិល ។ តួនាទីរបស់ PFCC គឺដើម្បីផ្តល់ឱវាទជូនរដ្ឋសភាអំពីគ្រប់កិច្ចការទាំងអស់ ដែលទាក់ទិននឹងមូលនិធិប្រេងកាតទីម័រឡេស្តេ (TLPF) និងអំពីចំណាយនៅពេលណាដែលចំណាយច្រើនជាងចំណូលគណនាប្រកបដោយចីរភាពនៃមូលនិធិនេះ ។

## សមត្ថភាពរបស់សម្ព័ន្ធភាព

សង្គមស៊ីវិលនៅប្រទេសទីម័រឡេស្តេ មិនសូវមានបទពិសោធន៍ទេក្នុងការឃ្លាំមើលចំណូលធន

ធាន ។ លើសពីនេះទៀត ធនធាន និងសមត្ថភាពបច្ចេកទេសរបស់សម្ព័ន្ធភាពនៅប្រទេសទីម័រឡេស្តេនៅមានកម្រិត ដោយសារប្រទេសនៅក្មេងខ្ចី និងទើបតែងើបចេញពីវិវាទ និងដោយសារឧស្សាហកម្មប្រេងកាតមានភាពថ្មីថ្មោង ។

លើសពីនេះទៀត ការសម្របសម្រួលលើការឃ្លាំមើល និងសកម្មភាពតស៊ូមតិ (ដែលត្រូវបានធ្វើតាមរយៈសម្ព័ន្ធភាព) ដែលសំដៅលើតម្លាភាពចំណូលធនធាន គឺទន់ខ្សោយ ។ ទោះជាយ៉ាងណាក្តី ក៏សមាជិកនៃសម្ព័ន្ធភាពនៅប្រទេសទីម័រឡេស្តេមានទំនាក់ទំនងរឹងមាំជាមួយសហគមន៍មូលដ្ឋាន ដោយមានសមាជិកមួយចំនួនកំពុងចូលរួមក្នុងការឃ្លាំមើលថវិកានៅកម្រិតមូលដ្ឋាន ។

ការគាំទ្រចំពោះសម្ព័ន្ធភាពពីធនាគារពិភពលោកដែលបច្ចុប្បន្ននេះកំពុងជួយប្រទេសទីម័រឡេស្តេក្នុងកិច្ចដំណើរការអនុវត្ត EITI គឺមានសារសំខាន់ ។ ជំនួយគាំទ្រផ្សេងទៀតត្រូវបានផ្តល់តាមរយៈសម្ព័ន្ធភាពអន្តរជាតិសំខាន់ៗ ឬអង្គការសង្គមស៊ីវិលអន្តរជាតិនានា ដូចជា សម្ព័ន្ធភាពចេញផ្សាយអ្វីដែលអ្នកបានបង់ប្រាក់ (PWYP), CAFOD, អុកស្វាម (Oxfam), OSI និង អង្គការតម្លាភាពអន្តរជាតិ (Transparency International) ជាដើម ។

# វិធីសាស្ត្រនៃការពាក់ព័ន្ធ

## ជាមួយសង្គមស៊ីវិល

ក្នុងការសម្រេចបាននូវការលើកស្ទួយគណនេយ្យភាព និងតម្លាភាពនៃចំណូលធនធាននៅប្រទេសទីម័រឡេស្តេ សម្ព័ន្ធភាពជួបប្រទះការលំបាកដោយសារការខ្វះខាតសមត្ថភាព បច្ចេកទេសខ្ពស់របស់ខ្លួន ។ ប៉ុន្តែ ពួកគេបានទទួលមូលនិធិច្រើន និងត្រូវបានផ្សារភ្ជាប់ទៅក្នុងបណ្តាញគាំទ្រដើម្បី ជំនួយបច្ចេកទេស និងធនធានពីគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិធនាគារពិភពលោក (និងមូលនិធិរូបិយវត្ថុអន្តរជាតិ) ម្ចាស់ជំនួយ (Norad, Dfid, USAID) និងអង្គការមិនមែន




*រូបភាព: សន្និសីទថ្នាក់ជាតិ ស្តីពីឧស្សាហកម្មប្រេងកាត រៀបចំដោយ: លូតា ហាមាទុក ប្រទេសទីម័រឡេស្តេ ។ រូបភាពដោយ លូតា ហាមាទុក*

រដ្ឋាភិបាល អន្តរជាតិ (PWYP, OSI, RWI, CAFOD, GuksVam (Oxfam), TI) ។ អង្គការទាំងនេះផ្តល់ការជួយឧបត្ថម្ភ និងការចូលរួម ជាមួយក្រុមសង្គមស៊ីវិលក្នុងស្រុក និងពាក់ព័ន្ធយ៉ាងមានអត្ថន័យជាមួយរដ្ឋាភិបាល ប៉ុន្តែមិនសូវមានទាក់ទងច្រើនទេជាមួយសាជីវកម្មប្រេងកាត ។ ភារកិច្ចធំៗខ្លះរបស់សម្ព័ន្ធភាព ដើម្បីអត្ថប្រយោជន៍របស់ក្រុមសង្គមស៊ីវិលជាគ្នីគ្នា និងសាធារណៈជារួម រួមមានៈ ភាពជាតំណាង ចំពោះរដ្ឋាភិបាល និងសាជីវកម្ម ការផ្សព្វផ្សាយព័ត៌មាន ការពាក់ព័ន្ធជាមួយប្រព័ន្ធសារព័ត៌មានការ កសាងបណ្តាញ និងការទទួលបាននូវការគាំទ្រអន្តរជាតិ ។ ប៉ុន្តែ ការលំបាកចម្បងនៃការងារនេះច្រើន គឺជាការខ្វះខាតធនធាន និងសមត្ថភាព បច្ចេកទេស ។

## ការផ្សព្វផ្សាយព័ត៌មាន

នៅប្រទេសទីម័រឡេស្តេ សម្ព័ន្ធភាពពឹងផ្អែកភាគច្រើនលើអត្ថបទរបាយការណ៍ និងព្រឹត្តិប័ត្រជាភាសាដែលអាចយល់បាន ដើម្បីផ្សព្វផ្សាយព័ត៌មានជូនដល់ភាគីពាក់ព័ន្ធផ្សេងៗជាច្រើន និង ជម្រុញការយល់ដឹងសាធារណៈអំពីវិស័យប្រេងកាតនៅថ្នាក់ជាតិ និងអន្តរជាតិ និងផលប៉ះពាល់របស់វិស័យនេះលើសង្គមស៊ីវិល ។ ព័ត៌មានបែបនេះ ច្រើនត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយជូនស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការសង្គមស៊ីវិល រួមមាន ព្រះវិហារ និងអង្គការយុវជន សាលារៀន អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ម្ចាស់ជំនួយ និងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ។ កិច្ចការនេះ លើកស្ទួយការយល់ដឹងអំពីការបារម្ភរបស់សង្គមស៊ីវិលនៅក្នុង និងក្រៅប្រទេសទីម័រឡេស្តេ ។ វា ក៏ផ្តល់ផងដែរនូវច្រកសម្រាប់ឱ្យអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ម្ចាស់ជំនួយ គ្រឹះស្ថានហិរញ្ញវត្ថុ អន្តរជាតិ និងក្រុមអន្តរជាតិជួយក្នុងយុទ្ធនាការតស៊ូមតិនៅទីណាដែលអាចធ្វើបាន ។ គេហទំព័រមិនសូវបានប្រើ ច្រើនទេនៅក្នុងប្រទេស ដោយសារហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងលទ្ធភាពប្រើកុំព្យូទ័រដ៏ទន់ខ្សោយ ។

## ប្រព័ន្ធសារព័ត៌មាន

ប្រព័ន្ធសារព័ត៌មាននៅក្នុងប្រទេសទីម័រឡេស្តេ ត្រូវបានចាត់ទុកជាទូទៅថាមានលក្ខណៈឯករាជ្យ ។ ប៉ុន្តែ គេមើលឃើញថាគុណភាពនៃការរាយការណ៍ គឺខ្សោយ ហើយវិជ្ជាជីវៈសារព័ត៌មានស៊ើបអង្កេតហ្មត់ចត់នៅប្រទេសទីម័រឡេស្តេគឺមិនមានទេ ។ ប្រការនេះត្រូវបានធ្វើឱ្យមានលក្ខណៈកាន់តែធ្ងន់ធ្ងរថែមទៀតដោយការខ្វះខាតធនធានទូទៅ ដើម្បីបណ្តុះបណ្តាលអ្នកសារព័ត៌មានអំពីវិស័យប្រេងកាត និងបញ្ហាចំណូលធនធាន ។ ប្រព័ន្ធព័ត៌មានអាចជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់ធ្វើចលនាចំណាប់អារម្មណ៍សាធារណៈលើវិស័យប្រេងកាត ប្រសិនបើសម្ព័ន្ធភាពបន្តកសាងទំនាក់ទំនងល្អជាមួយអ្នកសារព័ត៌មាន ដើម្បីលើកស្ទួយចំណាប់អារម្មណ៍របស់អ្នកសារព័ត៌មានលើវិស័យប្រេងកាត និងដើម្បីកែលម្អជំនាញវិភាគ និងស៊ើបអង្កេតរបស់ពួកគេ ។ ជារួម ប្រព័ន្ធសារព័ត៌មាននៅក្នុងប្រទេសទីម័រឡេស្តេ

ជាទូទៅ ត្រូវបានគេយល់ថាគឺជាឧបករណ៍អប្រសិទ្ធភាពមួយសម្រាប់ជម្រុញការយល់ដឹងអំពីបញ្ហាតម្លាភាពនៃប្រាក់ចំណូលប្រេងកាត ។

## ការកសាងបណ្តាញ

បណ្តាញរវាងក្រុមសង្គមស៊ីវិលផ្សេងៗគឺ រឹងមាំគួរសម ថ្វីបើកម្រិតនៃការអភិវឌ្ឍ និងសមត្ថភាព បច្ចេកទេសរបស់ក្រុមជារួមគឺជាទូទៅមានលក្ខណៈទន់ខ្សោយខ្លាំង ។ គេឃើញមានផលប្រយោជន៍ដ៏ធំធេងរបស់ក្រុមក្នុងស្រុកដែលបានផ្សារភ្ជាប់ទៅនឹងចលនាជាតិ និងអន្តរជាតិដ៏ទូលាយនៅជុំវិញតម្លាភាព ចំណូលធនធាន ដោយសារពួកគេបានអភិវឌ្ឍប្រសើរជាង ដោយសារប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសដែល ទើបងើបចេញពីចលនាឯករាជ្យផ្អែកលើជនបទ ។ ប៉ុន្តែ នៅពេលដែលសម្ព័ន្ធភាពធំៗកាន់តែមានទំនុកចិត្ត សេចក្តីគោរព និងធនធាន គេឃើញមាននិន្នាការមួយឆ្ពោះទៅកាន់មជ្ឈការ និងកង្វះខាតការសម្របសម្រួលរួម ។ លើសពីនេះទៀត មតិមិនឯកភាពគ្នានៅក្នុងការតស៊ូមតិបន្សាបប្រសិទ្ធភាពសង្គមស៊ីវិលក្នុងការចូលរួមក្នុងបញ្ហាចំណូលធនធាន ។

## ការគាំទ្រ/ភាពជាដៃគូអន្តរជាតិ

រដ្ឋាភិបាលនៃប្រទេសទីម័រឡេស្តេ គាំទ្រការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងគំនិតផ្តួចផ្តើមពិភព លោកនានា ដូចជា EITI ជាដើម ។ បណ្តាញអន្តរជាតិសំខាន់ៗដូចជា PWYP និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានាដូចជា វិទ្យាស្ថានឃ្លាំមើលប្រាក់ចំណូល (Revenue Watch) CAFOD និងអុកស្វាម (Oxfam) ក៏ផ្តល់ការគាំទ្រ និងភាពជាដៃគូជាប់លាប់ជាមួយសម្ព័ន្ធភាពផងដែរ ។ ការគាំទ្រខ្លះ ក៏ត្រូវបានផ្តល់ផងដែរដោយគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ។ ជោគជ័យនៃកម្លាំងនៃការគាំទ្រនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធនាការតស៊ូមតិថ្មីៗនេះ ។ អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ និងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិសហការគ្នាប្រកបដោយជោគជ័យដើម្បីជម្រុញឱ្យរដ្ឋាភិបាលកាន់តែមានតម្លាភាព និង ឱ្យតាក់តែងឡើងវិញនូវច្បាប់នានាទាក់ទិននឹងវិស័យប្រេងកាត ។

## កង្វះធនធាននិង/ឬជំនាញ

ចំពោះសម្ព័ន្ធភាព និងសង្គមស៊ីវិលទូទៅដើម្បីឱ្យការចូលរួមកាន់តែមានប្រសិទ្ធភាពថែមទៀត នៅក្នុងតម្លាភាពចំណូលធនធាន ពួកគេចាំបាច់ត្រូវកែលម្អជំនាញបច្ចេកទេស និងជំនាញចាត់ចែងរបស់ខ្លួន ។ ឧទាហរណ៍ សមត្ថភាពបច្ចេកទេសមានកម្រិតរបស់តំណាងសង្គមស៊ីវិលនៅក្នុងក្រុមការងារត្រីភាគី EITI និង នៅក្នុងក្រុមប្រឹក្សាពិគ្រោះយោបល់មូលនិធិប្រេងកាត អាចធ្វើឱ្យភាគីពាក់ព័ន្ធផ្សេងទៀត ដឹកនាំកិច្ចដំណើរការនេះ ដែលជាហេតុកាត់បន្ថយឥទ្ធិពលនៃការចូលរួមរបស់សង្គមស៊ីវិល ។ ការថយចុះនៃការជួយគាំទ្រអន្តរជាតិចំពោះការងារកសាងស្ថាប័ន និងកសាងសមត្ថភាពសម្រាប់ប្រទេសទីម័រ

ឡេស្តេ ធ្វើឱ្យបញ្ហានេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរ ។

# ជាមួយរដ្ឋាភិបាល

## អភិវឌ្ឍទំនាក់ទំនងការងារល្អ

ការកសាងទំនាក់ទំនងការងារអាចទុកចិត្តបានជាមួយមន្ត្រីពាក់ព័ន្ធ នៅក្នុងវិស័យសាធារណៈ និងនៅក្នុងវិស័យផ្សេងទៀត មិនមានជួបការលំបាកច្រើនទេនៅក្នុងប្រទេសទីម័រឡេស្តេ ។ គេឃើញមានទំនុកចិត្តគ្នា និងការគោរពគ្នាជាប់លាប់ជាមួយមន្ត្រីរដ្ឋាភិបាលយុទ្ធសាស្ត្រសំខាន់ៗ ។ ថ្វីបើសង្គមស៊ីវិល មិនមានផ្តល់ជំនាញបច្ចេកទេសច្រើនក្តី ក៏ការបារម្ភរបស់ពួកគេត្រូវបានដោះស្រាយបានប្រសើរបំផុតដែរ ប្រសិនបើពួកគេសំដៅមុខព្រួញលើមន្ត្រីរដ្ឋសភា និងមន្ត្រីរដ្ឋាភិបាលទាំងឡាយដែលគឺជាអ្នកគាំទ្រសង្គមស៊ីវិលដ៏ខ្លាំងក្លា ( មន្ត្រីខ្លះគឺជាអតីតតំណាងសង្គមស៊ីវិល) ។

តំណាងសង្គមស៊ីវិលខ្លះនៅប្រទេសទីម័រឡេស្តេមាន ចំណេះដឹងល្អអំពីបញ្ហាគន្លឹះនានាទាក់ទិននឹងវិស័យប្រេងកាតដែលអនុញ្ញាតឱ្យពួកគេអាចពាក់ព័ន្ធបានប្រសើរជាងជាមួយរដ្ឋាភិបាល ។ អ្នកដែលផ្តល់ការវិភាគល្អជាមួយបទដ្ឋានខ្ពស់ គឺមានប្រសិទ្ធភាពក្នុងការជម្រុញឱ្យរដ្ឋាភិបាលពិចារណាបញ្ហាតាមទស្សនៈរបស់សង្គមស៊ីវិល ។ ការផ្តល់ការវិភាគរឹងមាំ គួបផ្សំជាមួយនឹងការជួយគាំទ្រខាងបញ្ចុះបញ្ចូលពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ម្ចាស់ជំនួយ (និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ) ដើម្បីបញ្ចេញមតិឯកភាពតែមួយ គឺជាកត្តាដ៏សំខាន់មួយដើម្បីបង្កើនសក្តានុពលពាក់ព័ន្ធជាមួយ និងមានឥទ្ធិពលលើការអនុវត្តរបស់រដ្ឋាភិបាល ។

## កំណែទម្រង់រចនាសម្ព័ន្ធ

ច្បាប់ត្រូវបានគេចាត់ទុកថាតាក់តែងបានល្អជាមួយបទដ្ឋានខ្ពស់ ។ មុនពេល យកមកអនុវត្តគេចាំបាច់ត្រូវមានការអនុម័តយល់ព្រមពីដោយរដ្ឋសភាសិន ហើយទោះបីជាចេតនាល្អក្តី ក៏សមត្ថភាពធ្វើច្បាប់អនុវត្ត និងធ្វើនិយ័តកម្មទន់ខ្សោយនៅឡើយដែរ ។ ម្យ៉ាងទៀត ចំពោះមុខស្ថានភាពទន់ខ្សោយនៃកិច្ចអភិវឌ្ឍន៍ស្ថាប័ននៅក្នុងប្រទេស ក៏ដូចជាចលាចលនយោបាយនាពេលថ្មីៗនេះដែរ ច្បាប់ល្អច្រើនមានតែនៅក្នុងសៀវភៅ ជាជាងឆ្លុះបញ្ចាំងជាក់ស្តែងនៅក្នុងការអនុវត្តប្រកបដោយប្រសិទ្ធិភាព ។ គេនៅមានការងារធ្វើច្រើនទៀត ដើម្បីកសាងសមត្ថភាពធនធានមនុស្ស និងស្ថាប័នរបស់ប្រទេសទីម័រឡេស្តេ ។ ទស្សនៈរួមពីតំណាងសង្គមស៊ីវិលគឺថា បើគ្មានបុគ្គលិកជំនាញរដ្ឋាភិបាលទេ និងចំពោះមុខកង្វះខាតស្ថាប័នសាធារណៈប្រកបដោយសមត្ថភាពដើម្បីឃ្លាំមើលដំណើការអភិបាលកិច្ចល្អ វាគឺជាការពិបាកដែលសង្គមស៊ីវិលអាចចូលរួមប្រកបដោយប្រសិទ្ធភាព ។ ច្បាប់ស្តីពីសិទ្ធិនៃព័ត៌មាន នៅមិនទាន់បាន

បង្កើតនៅឡើយ ហើយទោះបីជាក្រុមសង្គមស៊ីវិលខ្លះ និយាយថាមានការលំបាកក្នុងការទទួលបានព័ត៌មានលម្អិតក្តី ក៏ការយល់ឃើញជារួម គឺថារដ្ឋាភិបាលបើកទូលាយបង្គួរ និងថាគេមិនមានការលំបាកទេក្នុងការរកព័ត៌មានពីមន្ត្រីរដ្ឋាភិបាល ។

នៅតាមប្រទេសទាំងឡាយដូចជាប្រទេសទីម័រឡេស្តេ ដែលស្ថិតក្រោមឥទ្ធិពលនៃចំណូលប្រេងកាត គេចាំបាច់ត្រូវពិចារណាកំណែទម្រង់រចនាសម្ព័ន្ធដើម្បីយន្តការអភិបាលកិច្ចល្អឱ្យបានទូលាយជាងដើម្បីដាក់បញ្ចូលកិច្ចដំណើរការគ្រប់គ្រងវិស័យសាធារណៈជារួម បរិស្ថានអាជីវកម្មនិងវិនិយោគ និងគោលនយោបាយសេដ្ឋកិច្ចនិងសង្គមកិច្ច ។ គេឃើញមានកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធខ្លះ ។ កម្មវិធីខ្លះយកចិត្តទុកដាក់ដោយផ្ទាល់លើវិស័យប្រេងកាត ខណៈដែលកម្មវិធីផ្សេងទៀតមានផលប៉ះពាល់ប្រយោលលើវិស័យប្រេងកាត តាមរយៈការកែលម្អទុទៅនូវយន្តការតម្លាភាព និងអភិបាលកិច្ច ។ លើសពីនេះទៀតគម្រោងខ្លះនៃគម្រោងទាំងនេះត្រូវបានអនុវត្តតាមរយៈអង្គការសង្គមស៊ីវិល ។

គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និងម្ចាស់ជំនួយសំខាន់ៗនៅក្នុងប្រទេសទីម័រឡេស្តេបច្ចុប្បន្នដែលគាំទ្រកម្មវិធីនានាដែលផ្តោតលើកំណែទម្រង់រចនាសម្ព័ន្ធនៅក្នុងរដ្ឋាភិបាល រួមមានៈ ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលណ័រវ៉េ រដ្ឋាភិបាលអូស្ត្រាលី (AusAID) និង អង្គការអុកស្វាមអូស្ត្រាលី (Oxfam Australia) ។

## ឆន្ទៈនយោបាយ

ឆន្ទៈនយោបាយគឺរឹងមាំប្រាកដមែនដើម្បីលើកស្ទួយការអនុវត្តអភិបាលកិច្ចល្អនៅក្នុងកិច្ចដំណើរការរដ្ឋបាលនៃវិស័យសាធារណៈទាំងមូល (រួមទាំងការគ្រប់គ្រងចំណាយសាធារណៈផងដែរ) ។ ប៉ុន្តែ សមត្ថភាពរបស់វិស័យសាធារណៈដើម្បីសម្រេចបានគោលដៅនេះ គឺមានកម្រិត ។ ជាទូទៅ សង្គមស៊ីវិល និងរដ្ឋាភិបាលនៅប្រទេសទីម័រឡេស្តេមានទំនាក់ទំនងការងារល្អ ។ ប៉ុន្តែ សមត្ថភាពនិងធនធានរបស់ សង្គមស៊ីវិលគឺមានកម្រិត ដែលកាត់បន្ថយលទ្ធភាពរបស់ខ្លួនក្នុងការធ្វើការសហការប្រកបដោយប្រសិទ្ធិភាពជាមួយរដ្ឋាភិបាល ។ លើសពីនេះទៀត ការសម្របសម្រួលសង្គមស៊ីវិលដើម្បីធ្វើការងារឱ្យបានកាន់តែមានប្រសិទ្ធភាពថែមទៀតជាមួយរដ្ឋាភិបាល ចាំបាច់ត្រូវកែលម្អ ។

គេឃើញមានឆន្ទៈនយោបាយដើម្បីអនុវត្តកិច្ចដំណើរការ EITI ។ ទោះបីជាវឌ្ឍនភាពមានលក្ខណៈយឺតក្តី ក៏នៅពេលថ្មីៗនេះ រដ្ឋាភិបាលបានបញ្ជាក់អះអាងឡើងវិញនូវការប្តេជ្ញាជាបន្តរបស់ប្រទេសទីម័រឡេស្តេចំពោះ EITI និង ឆន្ទៈរបស់ខ្លួនក្នុងការចេញផ្សាយរបាយការណ៍ EITI ទីមួយរបស់ខ្លួន ។

## ជាមួយសាធារណជន

រហូតមកដល់ពេលថ្មីៗនេះ ទោះបីជាមានការបង្កើតក្រុមការងារត្រីភាគី (EITI) ក្តី ក៏ក្រុមហ៊ុនប្រេងកាតមិនសូវមានទំនាក់ទំនងជាមួយតំណាងសង្គមស៊ីវិល ឬមានវត្តមាននៅក្នុងប្រទេសទីម័រឡេស្តេទេ។ សកម្មភាពប្រេងកាតទាំងអស់មកដល់ពេលនេះនៅក្នុងប្រទេសទីម័រឡេស្តេ បានកើតឡើងនៅក្នុងសមុទ្រ ហើយទើបតែក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះប៉ុណ្ណោះ ដែលគេឃើញមានប្រតិបត្តិករធំៗ ដូចជា ក្រុមហ៊ុនកូណូកូហ្វីលីព (ConocoPhillips) ជាដើម បានបង្កើតការិយាល័យនៅក្នុងប្រទេសទីម័រឡេស្តេ។

# មេរៀនសម្រាប់សង្គមស៊ីវិល

## បង្កើតសម្ព័ន្ធភាពតំណាងមួយ

### សម្ព័ន្ធភាពមួយដើម្បីឃ្លាំមើលថវិកា

សង្គមស៊ីវិលចាំបាច់ត្រូវពិចារណាអំពីផលប្រយោជន៍សក្តានុពលនៃការបង្កើតសម្ព័ន្ធភាពដោយឡែកមួយដែលឃ្លាំមើលការប្រើប្រាស់ប្រាក់ចំណូលប្រេងកាតនៅក្នុងយន្តការថវិការដ្ឋ ។

### សម្ព័ន្ធភាពដើម្បី EITI

ការធ្វើចលនារបស់សង្គមស៊ីវិលដើម្បីបង្កើតសម្ព័ន្ធភាពមួយគឺសំខាន់ដើម្បីផ្តល់កម្លាំងរួម និងមតិឯកភាពស្របច្បាប់មួយក្នុងការពិនិត្យមើលកិច្ចដំណើរការអនុវត្ត EITI ។ សមាជិកសម្ព័ន្ធភាពចាំបាច់មិនត្រូវស្ថិតនៅក្រោមឥទ្ធិពលរបស់រដ្ឋាភិបាល ឬក្រុមហ៊ុនឡើយ ។

### ប្រសិទ្ធិភាពនៃសម្ព័ន្ធភាព

ដើម្បីធានាប្រសិទ្ធិភាពឱ្យបាន សម្ព័ន្ធភាពចាំបាច់ត្រូវពិចារណាចំណុចខាងក្រោមនេះ:

- ភាពចាំបាច់ត្រូវមានសម្ព័ន្ធភាពពីរដោយឡែកពីគ្នា ឬសម្ព័ន្ធភាពមួយដែលផ្តោតលើកិច្ចដំណើរការ EITI ផង និងការប្រើប្រាស់ប្រាក់ចំណូលប្រេងកាតផង
- គោលដៅច្បាស់លាស់ និងសកម្មភាពសម្រាប់សម្ព័ន្ធភាពនេះ
- លក្ខខណ្ឌសមាជិកភាព (រួមមាន ទំហំ និងសមាសភាពនៃសម្ព័ន្ធភាព)
- នីតិវិធី និងយន្តការសម្រាប់កំណត់និងឯកភាពលើសកម្មភាពនានារបស់សម្ព័ន្ធភាព
- នីតិវិធី និងយន្តការសម្រាប់រៀបចំនិងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពទាំងឡាយដែលត្រូវអនុវត្តន៍ដោយសម្ព័ន្ធភាព
- កំណត់ឧបសគ្គដែលអាចមាននៅក្នុងធនធាននិងសមត្ថភាព និងគិតគូរអំពីជម្រើសនានាដើម្បីបំពេញតាមលក្ខខណ្ឌទាំងនេះ ។

## ផ្តោតលើបញ្ហាគន្លឹះ: EITI

### ប្តេជ្ញាចំពោះ EITI

ជម្រុញឱ្យរដ្ឋាភិបាលអនុម័តកិច្ចដំណើរការអនុវត្ត EITI ។ ការគាំទ្រចំពោះយុទ្ធនាការនេះគប្បីត្រូវបានស្វែងរកពីអង្គការជាតិ និងអន្តរជាតិ និងសម្ព័ន្ធភាពសំខាន់ៗផ្សេងទៀតជាពិសេស: ធនាគារពិ

ភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សម្ព័ន្ធភាពចេញផ្សាយអ្វីដែលអ្នកបានបង់ប្រាក់ (PWYP) OSI វិទ្យាស្ថានឃ្លាំមើលប្រាក់ចំណូល (Revenue Watch Institute) ។

## ចូលរួមក្នុងក្រុមការងារត្រីភាគី EITI

សមាជិកនៃក្រុមការងារត្រីភាគី EITI នេះ ដោយមានតំណាងពីរដ្ឋាភិបាល ឧស្សាហកម្ម និងសង្គមស៊ីវិល) ចាំបាច់ត្រូវឆ្លុះបញ្ចាំងតុល្យភាពនៃផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ ។ ហេតុនេះ នៅក្នុងក្រុមការងារ EITI សង្គមស៊ីវិលចាំបាច់ត្រូវ:

- តស៊ូមតិដើម្បីភាពជាតំណាងពិតប្រាកដរបស់សង្គមស៊ីវិលដែលឆ្លុះបញ្ចាំងតុល្យភាពភាគីពាក់ព័ន្ធ
- ជ្រើសរើសតំណាងរបស់ខ្លួនដោយខ្លួនឯង - មិនស្ថិតក្រោមឥទ្ធិពលរបស់រដ្ឋាភិបាលឬក្រុមហ៊ុន
- ជ្រើសរើសសមាជិកដែលមានសមត្ថភាពបច្ចេកទេសដែលអនុញ្ញាតឱ្យពួកគេអាចចូលរួមប្រកបដោយប្រសិទ្ធិភាព ។

## ចូលរួមក្នុងការរាយការណ៍ EITI

វាគឺជាប្រការសំខាន់ដែលទម្រង់រាយការណ៍ EITI ត្រូវដាក់បញ្ចូលសំណើរបស់សង្គមស៊ីវិល ។ ដូចនេះ សង្គមស៊ីវិលចាំបាច់ត្រូវតស៊ូមតិយ៉ាងខ្លាំងក្លាដើម្បីវិសាលភាព និងប្រភេទជាក់លាក់នៃការបញ្ចេញព័ត៌មានដែលត្រូវដាក់បញ្ចូលនៅក្នុងទម្រង់រាយការណ៍EITI ជាពិសេស នៅពេលចាប់ផ្តើមនៃកិច្ចដំណើរការអនុវត្ត ។

សេចក្តីសម្រេចចិត្តអំពីវិសាលភាពនៃការរាយការណ៍ ទំនងជានឹងត្រូវបានធ្វើផ្អែកលើរបបសារពើពន្ធ ដែលភាគច្រើន នឹងគឺជាកិច្ចព្រមព្រៀងអនុវត្តបានតាមកិច្ចសន្យារវាងក្រុមហ៊ុន និងរដ្ឋាភិបាល ។ គេក៏ឃើញមានផងដែរនូវសក្តានុពលដែលក្រុមហ៊ុនខ្លួនឯងបញ្ចេញព័ត៌មានជាសាធារណៈអំពីការបង់ប្រាក់របស់ខ្លួនជូនរដ្ឋាភិបាល ដែលសង្គមស៊ីវិលគប្បីគាំទ្រ ។

## ផ្តល់យោបល់លើរបាយការណ៍ EITI

ផ្តល់ទស្សនៈរួមមួយ (ឧទាហរណ៍ តាមរយៈរបាយការណ៍សម្ព័ន្ធភាពមួយ) អំពីរបាយការណ៍របស់រដ្ឋាភិបាល និងសវនករ ។ របាយការណ៍សម្ព័ន្ធភាពចាំបាច់ត្រូវផ្សព្វផ្សាយឱ្យបានទូលាយ ។ ព័ត៌មាននៅក្នុងរបាយការណ៍នេះ គប្បីមានលក្ខណៈច្បាស់លាស់ងាយយល់ និងផ្តល់ជូនជាភាសាក្នុងស្រុក ។ លើសពីនេះទៀត យុទ្ធនាការបង្កើនការយល់ដឹងសាធារណៈអំពីកិច្ចដំណើរការ EITI និងរបាយការណ៍ EITI ផ្សេងៗ ចាំបាច់ត្រូវធ្វើឱ្យបានទៀងទាត់ ។

# ផ្តោតលើបញ្ហាគន្លឹះៈ មូលនិធិប្រេងកាត

## ដាក់បញ្ចូលមូលនិធិទៅក្នុងថវិការដ្ឋ

មូលនិធិប្រេងកាតគប្បីដាក់បញ្ចូលទៅក្នុងដំណើការរៀបចំថវិកា ដើម្បីរក្សាការគ្រប់គ្រងឯកភាពមួយលើគោលនយោបាយសារពើពន្ធ និងដើម្បីសម្រួលដល់ការសម្របសម្រួលចំណាយ ។ ចំណាយចេញពីមូលនិធិនេះគប្បីត្រូវទទួលការយល់ព្រមពីរដ្ឋសភា ។ ការរៀបចំ និងការរាយការណ៍ថវិកាគប្បីគឺជាការបង្ហាញរួមមួយ ។

## បង្កើតច្បាប់

ច្បាប់ចាំបាច់ត្រូវចែងឱ្យបានច្បាស់លាស់អំពីវិធានសម្រាប់មូលនិធិនេះ ដែលគប្បីមានតម្លាភាព និងចាកផុតពីការជ្រៀតជ្រែកនយោបាយ ។ ច្បាប់នេះគប្បីចែងពីៈ

- គោលបំណងនៃមូលនិធិនេះ
- ប្រភេទប្រាក់ចំណូលដែលត្រូវប្រមូល
- វិធាននានាដែលបានបង្កើតដើម្បីគ្រប់គ្រងការបញ្ចេញប្រាក់ចំណូល
- ទោសប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងមិនត្រឹមត្រូវលើមូលនិធិនេះ និងប្រាក់ចំណូលរបស់មូលនិធិ
- រចនាសម្ព័ន្ធអភិបាលកិច្ច និងការទទួលខុសត្រូវ ដែលរួមមានតួនាទី មុខងារ អំណាច សមាជិកភាពដែលពាក់ព័ន្ធក្នុងការគ្រប់គ្រង និងប្រតិបត្តិការ ។

## ផ្តល់ការត្រួតពិនិត្យឯករាជ្យ

អភិបាលកិច្ចរឹងមាំ គួបផ្សំជាមួយការត្រួតពិនិត្យប្រយ័ត្នប្រយែង ដែលត្រូវបានផ្តល់ដោយ ក្រុមប្រឹក្សាឯករាជ្យដែលមានសមាសភាពតែងតាំងដោយស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និង សង្គមស៊ីវិល ដែលផ្សារភ្ជាប់គ្នាដោយប្រព័ន្ធគណនេយ្យភាពទៅវិញទៅមកមួយ ចាំបាច់ត្រូវមានអត្ថិភាព ដើម្បីការគ្រប់គ្រងមូលនិធិនេះឱ្យបានល្អ ។

## មានការចូលរួមពិគ្រោះយោបល់សាធារណៈ

ជម្រុញឱ្យរដ្ឋាភិបាលធ្វើការពិគ្រោះយោបល់សាធារណៈមុនពេលបង្កើតមូលនិធិ និងឱ្យដាក់បញ្ចូលធាតុចូលពិតប្រាកដរបស់សង្គមស៊ីវិលនៅក្នុងពេលបង្កើត និងតាក់តែងច្បាប់មូលនិធិ ។ បទប្បញ្ញត្តិសំខាន់ៗដែលត្រូវពិភាក្សា ចាំបាច់ត្រូវផ្សព្វផ្សាយឱ្យបានទូលាយ ជាភាសាដែលអាចយល់បាន និងក្នុងទម្រង់មួយដែលងាយយល់ ។

### គស្ទូចតិដើម្បីឱ្យមានគណនេយ្យភាពខ្សែបណ្តោយនិងខ្សែទទឹង

មូលនិធិនេះគប្បីត្រូវបានគ្រប់គ្រងតាមលក្ខខណ្ឌនៃគណនេយ្យភាពខ្សែបណ្តោយ និងខ្សែទទឹងទន្ទឹមគ្នា ដែលរារាំងឆន្ទានុសិទ្ធិរបស់តួអង្គតែម្នាក់ណាមួយនៅក្នុងរដ្ឋាភិបាលមិនឱ្យធ្វើសេចក្តីសម្រេចចិត្តលើការប្រើមូលនិធិនេះ ។ ចំណុចនេះចាំបាច់ត្រូវមានចែងនៅក្នុងច្បាប់ ។

### គស្ទូចតិដើម្បីការត្រួតពិនិត្យឯករាជ្យ

គេចាំបាច់ត្រូវបង្កើតក្រុមប្រឹក្សាត្រួតពិនិត្យឯករាជ្យមួយ (ក្រុមប្រឹក្សា) - ដែលរួមមានភាពជាតំណាងរបស់សង្គមស៊ីវិល ដែលឃ្លាំមើលស្នាដៃ និងប្រតិបត្តិការនៃមូលនិធិនេះ ដែលរួមមាននៅក្នុង បរិបទនៃដំណើការរៀបចំថវិកាប្រការដែលថាតើមូលនិធិទាំងនេះត្រូវបានប្រើប្រាស់យ៉ាងត្រឹមត្រូវឬទេ ។

# ពាក់ព័ន្ធសង្គមស៊ីវិល

## ការកសាងសមត្ថភាព

សម្ព័ន្ធភាពសង្គមស៊ីវិលចាំបាច់ត្រូវអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ដើម្បីចូលរួមយ៉ាងមានប្រសិទ្ធភាព ជាមួយភាគីពាក់ព័ន្ធផ្សេងទៀតនៅក្នុងវិស័យប្រេងកាត ដែលនៅក្នុងនោះ ការពិភាក្សាច្រើនមានលក្ខណៈបច្ចេកទេស ។

ដើម្បីឃ្លាំមើលប្រកបដោយប្រសិទ្ធិភាពលើការប្រមូល និងការប្រើប្រាក់ចំណូលប្រេងកាត (រួមទាំងការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចដំណើរការ EITI) សម្ព័ន្ធភាពសង្គមស៊ីវិលចាំបាច់ត្រូវកសាងសមត្ថភាពរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងបញ្ហាបច្ចេកទេសផ្សេងៗ ដែលរួមមានៈ

- ច្បាប់ទាក់ទិននឹងការអភិវឌ្ឍវិស័យប្រេងកាត និងការប្រមូលនិងការប្រើប្រាក់ចំណូល ប្រេងកាត
- លក្ខខណ្ឌនានានៃកិច្ចសន្យាចែកផលិតកម្ម
- ប្រភេទបង់ប្រាក់របស់ក្រុមហ៊ុនជូនរដ្ឋាភិបាលម្ចាស់ផ្ទះ
- កិច្ចដំណើរការអនុវត្ត និងការរាយការណ៍ EITI
- ច្បាប់ពន្ធដារ និងរបបប្រមូលពន្ធ
- នីតិវិធីថវិការដ្ឋ
- យន្តការនៃមូលនិធិប្រេងកាត និងទំនាក់ទំនងរបស់វាទៅនឹងថវិការដ្ឋ
- ផលប៉ះពាល់សារពើពន្ធដែលអាចមានដោយសារប្រាក់ចំណូលបានមកពីវិស័យប្រេងកាត និង

ផលប៉ះពាល់លើម៉ាក្រូសេដ្ឋកិច្ច

- យន្តការឃ្លាំមើល និង ឧទាហរណ៍នៃការងារពីប្រទេសផ្សេងទៀតដែលពឹងផ្អែកលើប្រេងកាត ។

### មតិឯកភាពជាមួយភាគីពាក់ព័ន្ធទាំងអស់

ធ្វើចលនាសហគមន៍អន្តរជាតិ (រួមមាន អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និងទីប្រឹក្សាអន្តរជាតិ) ដើម្បីតស៊ូមតិចំពោះរដ្ឋាភិបាលនិងក្រុមហ៊ុន ដោយមានមតិឯកភាពតែមួយ ។

### ផ្សព្វផ្សាយព័ត៌មានឱ្យបានទូលាយ

ផ្សព្វផ្សាយព័ត៌មាន (រួមទាំងព័ត៌មានដែលបានធ្វើវិភាគរួច) ដល់ស្ថាប័នផ្សេងៗឱ្យបានទូលាយ (រួមមាន រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ម្ចាស់ជំនួយ និងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ) ដើម្បីលើកស្ទួយការយល់ដឹង ។ ចំណុចនេះក៏គប្បីផ្តល់ផងដែរនូវច្រកសម្រាប់ឱ្យអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ម្ចាស់ជំនួយ គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និងក្រុមអន្តរជាតិជួយក្នុងយុទ្ធនាការតស៊ូមតិ ។

## ពាក់ព័ន្ធរដ្ឋាភិបាល

### ទំនាក់ទំនងការងាររឹងមាំ

វិនិយោគនូវពេលវេលាដើម្បីបង្កើតទំនាក់ទំនងការងាររឹងមាំ (បណ្តាញ) ជាមួយមន្ត្រីសំខាន់ៗនៅតាមស្ថាប័នពាក់ព័ន្ធ ។ ប្រការនេះ អាចគឺជាអត្ថប្រយោជន៍ទៅវិញទៅមកសម្រាប់ភាគីទាំងអស់ ។

### ការវិភាគនិងការស្រាវជ្រាវប្រកបដោយគុណភាព

ផ្តល់ការវិភាគរឹងមាំផ្អែកលើភស្តុតាងដើម្បីតស៊ូមតិប្រកបដោយប្រសិទ្ធភាព ចំពោះរដ្ឋាភិបាលលើបញ្ហានានាទាក់ទិននឹងវិស័យប្រេងកាត និងការបារម្ភរបស់សង្គមស៊ីវិល ។

### ក្របខ័ណ្ឌច្បាប់

ជម្រុញឱ្យរដ្ឋាភិបាលរៀបចំវិធានការការពារសមស្រប រួមមានគោលការណ៍ណែនាំច្បាស់លាស់ដែលបង្ហាញពីដំណើការអនុវត្តអភិបាលកិច្ចល្អនៅតាមវិស័យទាំងឡាយ ដែលនៅក្នុងនោះ មានការកិបកេងធំៗ អាចកើតឡើង ។ វិស័យទាំងនោះ រួមមានៈ

- របបផ្តល់អាជ្ញាប័ណ្ណ ដោយសារក្រុមហ៊ុនពហុជាតិគឺឆ្លាតណាស់ក្នុងការផ្ទេរចំណេញ (ជាពិសេស

ទៅកាន់យុត្តាធិការដែលមានការហូតពន្ធទាប)

- ក្រុមហ៊ុនរដ្ឋធំៗ (ឧទាហរណ៍ ក្រុមហ៊ុនប្រេងកាតរដ្ឋ) ។

### ការចេញថ្លៃយកអាជ្ញាប័ណ្ណ

គេត្រូវរៀបចំនីតិវិធីប្រកបដោយតម្លាភាពមួយ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណប្រគល់សិទ្ធិរុករក ។ សង្គមស៊ីវិលគប្បីតស៊ូមតិចំពោះរដ្ឋាភិបាលដើម្បីឱ្យមាននីតិវិធីចេញថ្លៃក្នុងលក្ខណៈប្រកួតប្រជែង ដោយមានអ្នកវាយតម្លៃឯករាជ្យនៅក្នុងគណៈកម្មាធិការធ្វើសេចក្តីសម្រេចចិត្ត ។

### ការគាំទ្រពីសម្ព័ន្ធភាពអន្តរជាតិ

ពង្រឹងទំនាក់ទំនងជាមួយអង្គការ និងបណ្តាញពិភពលោកដែលផ្តល់ការគាំទ្រផ្នែកតស៊ូមតិដើម្បីដាក់សម្ពាធលើរដ្ឋាភិបាល និងក្រុមហ៊ុនឱ្យធ្វើការជាមួយសង្គមស៊ីវិលតាមរយៈកិច្ចដំណើរការនានា ដូចជា EITI ជាដើម ។ ភាពជាដៃគូបែបនេះក៏មានលទ្ធភាពអាចជួយក្រុមក្នុងស្រុកផងដែរ តាមរយៈការផ្តល់យោបល់អំពីច្បាប់ទាក់ទិននឹងវិស័យប្រេងកាត និងការកសាងសមត្ថភាពបច្ចេកទេស ។

## ពាក់ព័ន្ធក្រុមហ៊ុន

### បង្កើតទំនាក់ទំនងក្រៅផ្លូវការ

ព្យាយាមបង្កើតទំនាក់ទំនងក្រៅផ្លូវការដើម្បីអាចផ្លាស់ប្តូរគំនិត និងចំណាប់អារម្មណ៍គ្នាជាមួយនឹងសក្តានុពលកសាងភាពជាដៃគូការងាររឹងមាំ ។ គុណភាពនៃភាពជាដៃគូ គប្បីរួមមានការយល់ដឹងល្អអំពីបញ្ហាក្នុងស្រុក បណ្តាញរឹងមាំជាមួយសហគមន៍ និងពាក់ព័ន្ធនឹងបញ្ហានានាក្នុងវិស័យប្រេងកាត ។

### ការកសាងសមត្ថភាព

ជម្រុញឱ្យក្រុមហ៊ុនជួយគាំទ្រការកសាងសមត្ថភាពរបស់ក្រុមសង្គមស៊ីវិលលើវិស័យប្រេងកាត ក៏ដូចជា ការឃ្លាំមើលប្រតិបត្តិការក្រុមហ៊ុន ។ សម្ព័ន្ធមិត្តអាចត្រូវបានបង្កើតឡើងនៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ម្ចាស់ជំនួយ និងក្រុមហ៊ុន ដើម្បីផ្តល់ការបណ្តុះបណ្តាលចាំបាច់ ។

### ការបង្កើតគណៈកម្មាធិការឯករាជ្យមួយដើម្បីផ្តល់ការត្រួតពិនិត្យឯករាជ្យ

វាយតម្លៃលទ្ធភាពនៃការបង្កើតគណៈកម្មាធិការជាតិនិង/ឬអន្តរជាតិឯករាជ្យដើម្បីពិនិត្យមើលផលប៉ះពាល់នៃប្រតិបត្តិការក្រុមហ៊ុនប្រេងកាតលើសហគមន៍ ។ សង្គមស៊ីវិលក៏ចាំបាច់ត្រូវវាយតម្លៃផងដែរនូវលទ្ធភាពនៃការធ្វើការជាមួយរដ្ឋាភិបាលតាមរយៈគណៈកម្មាធិការទាំងនេះ ។

## យន្តការផ្សេងទៀតសម្រាប់ពាក់ព័ន្ធក្រុមហ៊ុន

វាគឺជាការលំបាកក្នុងការសុំឱ្យក្រុមហ៊ុនដោះស្រាយសេចក្តីត្រូវការរបស់សហគមន៍ ប្រសិនបើការរុករកធនធានកើតឡើងនៅក្នុងសមុទ្រ ហើយពុំមានបំពង់តឆ្លងកាត់ប្រទេស ។ ក្នុងស្ថានភាពបែបនេះ សង្គមស៊ីវិលចាំបាច់ត្រូវរិះរកវិធីផ្សេងទៀត ដើម្បីពាក់ព័ន្ធយ៉ាងមានប្រសិទ្ធិភាពជាមួយក្រុមហ៊ុន ។

## វត្តមាននៃផ្នែកឯកជន

ក្នុងករណីដែលពុំមានក្រុមហ៊ុននិស្សារណៈឯកជនស្ថិតនៅក្នុងប្រទេសម្ចាស់ផ្ទះ (ដោយសារសកម្មភាពក្នុងសមុទ្រ) សង្គមស៊ីវិលចាំបាច់ត្រូវតស៊ូមតិឱ្យមានតំណាងក្រុមហ៊ុនក្នុងប្រទេសមួយ ឬសុំឱ្យរដ្ឋាភិបាលកំណត់ជាលក្ខខណ្ឌមួយឱ្យក្រុមហ៊ុនបង្កើតការិយាល័យមួយ ។

# ឈ្មោះអក្សរកាត់

| | | |
|---|---|---|
| ADB | Asia Development Bank<br>ធនាគារអភិវឌ្ឍន៍អាស៊ី |
| BP | British Petroleum<br>ក្រុមហ៊ុនប្រេងកាតអង់គ្លេស |
| CAFOD | Catholic Agency for Overseas Development<br>ទីភ្នាក់ងារកាតូលិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| CDAP | Caspian Development Advisory Panel (Azerbaijan)<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍តំបន់សមុទ្រកាសព្យៀន ( ប្រទេសអាហ្សែរបៃហ្សង់) |
| CGT | Core Group for Transparency (Timor-Leste)<br>ក្រុមស្នូលដើម្បីតម្លាភាព ( ប្រទេសទីម័រឡេស្តេ) |
| CRRT | Cambodians for Resource Revenue Transparency<br>សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន |
| CSO | Civil Society Organization<br>អង្គការសង្គមស៊ីវិល |
| DFID | Department For International Development<br>ទីភ្នាក់ងារជំនួយអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស |
| EBRD | European Bank for Reconstruction and Development<br>ធនាគារអឺរ៉ុបដើម្បីស្តារ និងអភិវឌ្ឍន៍ |
| EITI | Extractive Industries Transparency Initiative<br>គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម |
| EU | European Union<br>សហភាពអឺរ៉ុប |
| FOI | Freedom of Information<br>សេរីភាពព័ត៌មាន |
| FONGTIL | Timor-Leste NGO Forum<br>វេទិកាអង្គការមិនមែនរដ្ឋាភិបាលទីម័រឡេស្តេ |
| GDP | Gross Domestic Product<br>ផលិតផលក្នុងស្រុកសរុប |

| | |
|---|---|
| IFI | International Financial Institute<br>គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ |
| IMF | International Monetary Fund<br>មូលនិធិរូបិយវត្ថុអន្តរជាតិ |
| INGO | International Non-Government Organization<br>អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| NBG | National Budget Group (Azerbaijan)<br>ក្រុមថវិកាជាតិ ប្រទេសអាហ្សែរបៃហ្សង់) |
| NGO | Non-Government Organization<br>អង្គការមិនមែនរដ្ឋាភិបាល |
| Norad | Norwegian Aid<br>ទីភ្នាក់ងារជំនួយអភិវឌ្ឍន៍អន្តរជាតិណ័រវ៉េ |
| OSI | Open Society Institute<br>វិទ្យាស្ថានសង្គមបើកទូលាយ |
| PFCC | Petroleum Fund Consultative Council (Timor Leste)<br>ក្រុមប្រឹក្សាពិគ្រោះយោបល់មូលនិធិប្រេងកាត ( ប្រទេសទីម័រឡេស្តេ) |
| PWYP | Publish What You Pay<br>សម្ព័ន្ធភាពចេញផ្សាយអ្វីដែលអ្នកបង់ប្រាក់ |
| RWI | Revenue Watch Institute<br>វិទ្យាស្ថានឃ្លាំមើលចំណូល |
| SOFAZ | State Oil Fund of Azerbaijan<br>មូលនិធិប្រេងកាតរដ្ឋនៃប្រទេសអាហ្សែរបៃហ្សង់ |
| TI | Transparency International<br>អង្គការតម្លាភាពអន្តរជាតិ |
| TLPF | Timor-Leste Petroleum Fund<br>មូលនិធិប្រេងកាតនៃប្រទេសទីម័រឡេស្តេ |
| USAID | United States Agency for International Development<br>ទីភ្នាក់ងារអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
*The NGO Forum on Cambodia*

ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង *Working Together for Positive Change*

អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង១ ភ្នំពេញ
ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទ: (+៨៥៥) ២៣ ២១៤ ៤២៩
ទូរសារ: (+៨៥៥) ២៣ ៩៩៤ ០៦៣
អ៊ីម៉ែល: ngoforum@ngoforum.org.kh
គេហទំព័រ: www.ngoforum.org.kh